រិម, ស្ងិម, ស្រិម ។ល។ តែគេនិយមជាយ៉ាងណាក៏ដោយក៏នៅតែអាចសរសេរទឹង ៉ + ម ជាដកបវែង ។ រឿរលែងតែពាក្យនោះជាពាក្យចាំបាច់ត្រូវសំស្ក្រឹត,

ដូចជា:

ពិម្ភ ពុម្ភ, សិម្ភៈ, ឆិម្ភ, ប្រឹមប្រឹយ ។ល។

២៣. បេទ្ធមហាត្ថៈគឌ្ឋ

នៅប្រទេសឥណ្ឌា មានសភាពផ្សេងពីប្រទេសដទៃ; ប្តូលិកលក្ខណៈ, កិច្ចរស់នៅដោយសុចរិត, ការប្តូរជីវិតរបស់ទូន ជាសភាពដែលគេពេញចិត្តជាងគេបំផុត ។ ក្នុងប៉ុន្មានចាំមុននេះ ទុត្តមគតិលោកគន្ធ ជាន ប្តូលទៅស្ថិតនៅក្នុងសាច់ឈាមពួកប្រជារាស្ត្រហិណ្ឌូ គ្រប់ជាន់ថ្នាក់; ទុត្តមគតិនោះជា ទុត្តមគតិរបស់ជាតិ ដែលដុះក្នុងសន្តានចិត្តគ្រប់ ៗ គ្នា, តែគុណភាពនឹងសេចក្តីពាប់អាន នៃពួកប្រជារាស្ត្រ មកពីប្តូលិកលក្ខណៈរបស់លោក; ឥឡូវនេះស្ថានការណ៍នេះបាយប្រទេសឥណ្ឌា មិនត្រូវនឹងគំនិតរបស់លោក, លោកគន្ធក្តៅក្រហល់ទៅជា ប្រឹងប្រែងខ្នះខ្នែងខាងសង្គមកិច្ច នឹងសេដ្ឋកិច្ចទៅវិញ ។ តែជាការភ័ន្តច្រឡំដោយពិត បើយើងស្មានថាសមត្ថភាពរបស់លោក ខាងផ្លូវនេះបាយបាយហិណ្ឌូជាវត្តអតីត: សមត្ថភាពនឹងពេលភាពនោះ ស្ថិតនៅ

ដដែល ហើយបើមានកិច្ចការខាងនយោបាយ ល្មមនឹង
ប្រព្រឹត្តទៅបាន លោកក៏សំដែងអានុភាពរបស់លោកក្នុង
ពេលនោះមិនខាន; លោកកម្រនឹងបាត់ការពេញលេញ តែ
បើការនោះ ត្រូវបំពេញដោយកលល្បិយកិច្ចដ៏ប្រសើរ លោក
កន្ធងផ្សែដោយម៉ឺងម៉ាត់ ។

ក. ពាក្យពន្យល់

លន្ទឹ = (ម.ព. កង្ខាអដ្ឋបទលេខ ៣៧) ។

សភាព = (ម.ព. កង្ខាអដ្ឋបទលេខ ៣) ។

បុគ្គលិកលក្ខណៈ (ម.ព. កង្ខាអដ្ឋបទលេខ ២៣) ។

សុបរិតត = (ម.ថ. សុបរិតត) ន. ការប្រព្រឹត្តល្អ, សេចក្តី-
ប្រតិបត្តិត្រឹមត្រូវ

គតិ = (ម.ព. កង្ខាអដ្ឋបទលេខ ៣៧) ។

ទុគ្គតិ = (ម.ព. កង្ខាអដ្ឋបទលេខ ២២) ។

ស្ថិតនៅ = កិ. តាំងនៅ, ដំកល់នៅ ។

ប្រជារាស្ត្រហិណ្ឌូ = ពពួកភស្ត្រជាតិសណ្ឋៅតាំងមូល ។

សង្គ្រាមបិត្តុ = (ម.ថ. សន់ - ជាន -) ន. បិត្តុគំនិតអធ្យាស្រ័យ

គុណភាព = (ម.ថ. គុណ:ភាព) ន. ភាពនៃគុណ, គុណ

ប្រយោជន៍ទូទៅ ។

ស្ថានការណ៍ = (ម.ថ. - ការ) ន. ហេតុការណ៍, រឿង

រ៉ាវ, ហេតុនៃទីតាំង ។

នយោបាយ = ន. ខ្មាយជាគ្រឿងដឹកនាំ (politique) ។

សង្គមកិច្ច = (ម.ថ. ស័ង - គំម:កិច) ន. កិច្ចការកង

សង្គម (action social) ។

សេដ្ឋកិច្ច = (ម.ថ. សេត - ឋ:កិច្ច) ន. កិច្ចការប្រៃសីរ

បំផុត, មុខរបរដ៏ឧត្តម, មុខការរបរដែលមានប្រយោជន៍ដ៏

សំខាន់ក្នុងប្រទេសនីមួយៗ (économie) ។

សម្ផត្តិភាព = (ម.ប. ស:ម័ត-ប:ភាព) ន. ភាពនៃ
សេចក្តីអាចហាន, ភាពនៃសេចក្តីមោះម៉ុត ។

អព៌ព = (ម.ប. អ:ឳត) គុ. ដែលកន្ទួលទៅហើយ,
ដែលហួសទៅហើយ ។

ឆបេភាព = (ម.ប. ព:ល:ភាប) ន. កំឡាំងកំហែង ។

អាឆុភាព = (ម.ប.-ភាប) ន. អំណាច, តេជះ,
សេចក្តីអង់អាច, សេចក្តីក្លាហាន ។

ករណីយកិច្ច = (ម.ប. ក:-រ៉:ណីយ:កិច) ន. កិច្ច
ដែលគួរធ្វើ, ការងារដែលត្រូវធ្វើ (devoir) ។

១. អក្ខរក្រុង

រស- រស់- រ៉ស់- រួស

រស = (ម.ប. រស់) ន. សម្ផស្ស (អាហារនេះមានរសឆ្ងាញ់) ។

រស់ = ក. មានជីវិតនៅ (រស់នៅមួយរយឆ្នាំ បើមានសេចក្តី

ប្រមាទ ឈោកឈៅថាវស់នៅឥតអំពើ ទុកស្មើដូចស្មាប់ឆៅហើយ) ។

រ៉ស់ = ន. ត្រីស្រែកាមួយយ៉ាង (ត្រីរ៉ស់) ។

រួស = គុ. ឬកិ.វិ. រហ័ស, ឆាប់ (មនុស្សរួសមាត់រួសក; រួសពន់, រួសកយ, រួសរ៉ាវ) ។

អំពីស្រៈ ◌ + ញ ទីឥស្រៈ ឩ + ញ

គិញ = ន. ចារបុរស ។

ញៀញ = គុ. ខាំស្រាលៗ (ញៀញម្ជុ) ។

ទិញ = កិ. ដូរយកវបស់ដែលខ្លួនត្រូវការដោយប្រាក់ (ទិញអង្ករ) ។

ទំនិញ = ន. វបស់ដែលត្រូវទិញ (ទំនិញឡើងថ្លៃ) ។

ធ្មេញ = ន. អាការក្នុងមាត់សម្រាប់ខាំទំពា (ធ្មេញកណ្តុរ, ធ្មេញក្របី, ធ្មេញត្រី) ។

ព្រលឹងខ្មែរ
www.learnkhmer.free.fr

ពេញ = គ. ឬ គ. វ. ធ្វើឲ្យដល់បំនួន, ដែលដល់បំនួន, ដល់មាត់: ទឹកពេញពាង; កាន់ពេញដៃ; ពេញក្រមុំ; បំពេញវិជ្ជា ។

មិញ = ន. រំពេច: គាលនោះមិញ, អម្បាញ់មិញ ។

រំញ ៗ = គ. វ. ដែលហូរតិចៗ: ទឹកហូរញ ៗ ។

រេញ = គុ. ទេញ, ក្រៃស, លូតលាស់បំរើនមិនរួច: សំបូងរេញ, ប្រសុីថ្នាំងរេញ ។

លិញ = ន. ឥហាន ។

លិញគំញ = ន. ឥហានសម្ងាត់, ចារបុរស ។

លេញ = ន. ឈ្មោះត្រីមួយប្រភេទ (ត្រីលេញ) ។

វិញ = និ. ទៀត, ដូចដែល (ត្រឡប់មកវិញ) ។

រេញ = គ. ត្រេកញ៉ាប់មញ្ជូលដួង (រេញខ្យែ, រេញគំនិត គា) ។

២៤. ស្រេដ្ឋកិច្ចប្រទេសគឺល្អៀសម័យមហាត្មៈគន្ធី

បើចង់យល់ច្បាស់នូវស្ថានការណ៍ប្រទេសឥណ្ឌៀ, គេ
ត្រូវយល់ហេតុការណ៍ពិតត្រឹមត្រូវ នៃស្ថានភាពលោកមហាត្មៈ
គន្ធី ដោយហេតុថា អាទិភាពនៃបុគ្គលិកលក្ខណៈរបស់
លោក គួរជាទីជ្រះថ្លាសម្បឹមអស្ចារ្យ ទាល់តែមិនយូរប៉ុន្មាន,
លោកអាចណែនាំឲ្យប្រជាជនយល់ហើយធ្វើតាមលោក,
ប្រតិបត្តិតាមលទ្ធិប្តូរតួមគតិរបស់លោក។ លោកជាដួងវិញ្ញាណ
បំពោះប្រជាជាតិឥណ្ឌៀទាំងមូល អាចញ៉ាំងឲ្យមនុស្សទាំង
ប្រទេសចលាចលបាន ។ ពួកមេនាយោបាយឯទៀតប្រឹង
ចូលមកដិតលោកទំាងយកលោកជាបង្អែក; លោកក៏បាន
ពន្យល់បក្ខពួកទាំងនោះ ឲ្យប្រតិបត្តិតាមមតនាយោបាយរបស់
កិច្ចរបស់លោក យកមតិនេះទៅអប់រំជនជាតិឥណ្ឌៀ ក្នុង
ភូមិនិគមជនបទ ឲ្យធ្វើតាមកម្មវិធីខ្នាតតូច ។ កម្មវិធី
នេះ គឺសេចក្តីប្រឹងនាយោបាយគ្រប់បែបយ៉ាងគ្រប់ជ្រុងជ្រោយ

ត្បាញរៃកបា្លសនៅតាមភូមិ ឧ.ធ.និយមប្រើតែសំពត់កបា្លស
ដែលឆ្នៃខ្លួនឯងមកស្លៀកពាក់; ពាក្យ "ខ័តជារ" ប្រែថា
"សំពត់អាចុះត្បាញនៅគ្រឹហ៍ខ្លួន" ។

ក. ពាក្យពន្យល់

សេដ្ឋកិច្ច= (ម. ព. កង្ឃអត្ថបទលេខ ៤៣) ។

សម័យ= (ម. ព. កង្ឃអត្ថបទលេខ ៣៧) ។

ស្ថានការណ៍= (ម. ព. កង្ឃអត្ថបទលេខ ៤៣)។

ស្ថានភាព= (ម. ព. កង្ឃអត្ថបទលេខ ៤៧)

អាទុភាព= (ម. ព. កង្ឃអត្ថបទលេខ ៤៣)

បុគ្គលិកលក្ខណៈ= (ម. ព. កង្ឃអត្ថបទលេខ ៤៣) ។

បលាបល= (ម.ថ. ច:ល"-ចល់) គ. ជ្រុលជ្រើម, រាំដើម
រាំដួល ។

មិញ= (ម.ថ. ម:ត) ន. សេចក្តីយល់ឃើញ, គំនិត ។

កម្មវិធី= (ម.ថ.ភ័ម-ម:-) ន. របៀបនៃការងារ (programme) ។

គ្រឹហ= ន. ផ្ទះ (villa) ។

១.អក្ខរាវុទ្ធ

អំព៉ស្រៈ ◌ + ប ឧងស្រៈ ◌ + ប

គគ្រឹប= គុ. ដែលមានអាការគ្រិច ។ ដោយជង្ហឹប្ញុះ (ជង្ហឹប្ញុះគគ្រិច) ។

គ្រឹប= ភ. ចៀសវាង (ចោរគេចពីប៉ូលីស) ។

គ្រិប ។ = ភ. វិ. ដែលកំរើតញាប់ៗ (ជង្ហឹប្ញុះគ្រិចៗ) ។

គ្រែប= ន. ឈ្មោះឈើមួយយ៉ាង (ដើមគ្រែប) ។

គ្រែប= គុ. ឬភ. ដែលភ្លាត់សរសៃ (ដៃគ្រែប, គ្រែបដើង) ។

ឃ្លឹប= ន. ឈ្មោះក្របមួយយ៉ាង(ក្របឃ្លឹប) ។

ឈ្លៀប= គុ. ចាប់ច្របាច់ដើម្បីឲ្យបែក(ឈ្លៀចគៀច) ។

ញៀប= គុ. សង្កត់ឈ្លៀចបំពៀច (ញៀចសង្កៀច) ។

ទឹប= គុ· ប្រុចចាក់ដោយទ្រនិច (ឃ្មុំទឹច, ខ្យងទឹច) ។

ទ្រែងឹប= ន. អាយុវ: ស្រួចមុតមានពិស (ទ្រនិចឃ្មុំ)។

ធៀប= គុ. បិទកែក (ធ្វើការកុំឆ្លៀតកែក) ។

ធឹប= (ម.ព· ទិច) គុ.ឬ គុ.វិ. មិនដែលដាច់ (នៅជាប់ជាទឹប) ។

ប្រែទ្រៀប= គុ. ដេរប្រាច់ឲ្យរឹងាស (ប្រាទេចផ្ការសា)។

ពន្លឹប= គុ. ភ្លើឲ្យរលេច (ពន្លឺចទូក) ។

ពពឹប= គុ. ដែលសើមក្រខ្វក់ខ្លាំង (ដីសើមពពិច) ។

ពពៀប= ន. ឈ្មោះសត្វស្លាបមួយយ៉ាង (សត្វ

ពាពេច) ។

ពៅប៉ែ= (ម.ប. ពេប) ន. ពាក្យស័ដ៏ (ពាក្យ

ពេចន៍) ។

ព្រៃប= ក. ញាក់ទទាក់ស្ងាប (និយាយចំពោះលលក

ណ្ងាល) លលកព្រៃប ។

២៥. របៀបសូត្រសូន្មរកហ៊ា

ម្ដុនដំបូងត្រូវរៀនហាត់ទំកប្ដូហាត់សូត្រ ត្រង់សេចក្ដី
ដែលគួរបញ្ចេញបញ្ចូលតែម្នាក់ឯងឲ្យស្ទាត់ជាមុនបង្ហើយ សឹម
ចូលទៅសូត្រក្នុងទីប្រជុំតូច-ធំ ។ ពេលដែលសូត្រនោះ ត្រូវ
សូត្រមួយៗឲ្យច្បាស់ៗឲ្យពេញសម្លេង តែកុំឲ្យជ្រុលជល់ទៅ
ស្រែក ត្រូវលៃឲ្យល្មមជល់សំឡេង កុំឲ្យតឹងពេក ធូរពេក
កុំឲ្យញាប់ពេក រង្គើលពេក ឲ្យមានវគ្គមានឃ្លា, ត្រូវកាន់
ស្មារតីឯកាន់ចូកពាជាអ្នកនិងធឹង, កុំរាសដៃផ្ងារឡើងនឹង
ផាប់ចុះ, កុំក្រមាច់លេង, កុំស៊ីបខ្លួនឯងនាំឲ្យសាបចូកពា, បើ
ចង់សើចខ្លាំងទប់ពុំបាន ត្រូវបង្ហើសូត្រមួយស្របក់សិន ដល់
ស្រួលខ្យល់ សឹមសូត្រតទៅទៀត, ត្រូវតាំងចិត្តថា អ្នកស្ដាប់
នាំងអស់ស្មូនតែនៅក្រោមអំណាចឬ ក្រោមឧបាទរបស់ខ្លួន,
មិនត្រូវឱនឈ្ងោកឬងើបទៅលើទេ, មិនត្រូវចាលភ្នែកឲ្យ
ហួសពីបរិសទ្យអ្នកស្ដាប់, ត្រូវឆ្លៀតភ្នែកឲ្យរឹង អាចសម្លឹងអ្នក

ស្ពាប់មិនញាច, មិនត្រូវឧបដៃទឹមបង្អែះឬច្រត់ដៃទៅលើ
វត្ថុផ្សេងៗ ។ ពេលក្រោកឈរក្តី អង្គុយប៉ុនទៅវិញក្តី មិនត្រូវ
រហស់រួសពន់ពេកឬយឺតពេកទេ ។

ក. ពាក្យពន្យល់

សូត្រ=(ម ថ.សូត) ក. ឋាតាមសេចក្តីដែលសរសេរស្រាប់ៗ

សុំផ្លូរកហ៊ា= (ម.ថ. សុនទ·រ:ក:ហ៊ា) ន. សំដីគួរចង់ស្តាប់,
ពាក្យសម្រាប់ថ្លែងក្នុងសន្និបាត ។

រីគ្គ= (ម.ថ.រ័ក) ន. សង្កាត់, ក្រុម, ស្ទើរ ។

ស្នាវព្រី= (ម.ថ.ស្នាវដី) ន. សេចក្តីទឹកឃើញ, ការចាំបាន,
សតិ ។

ក្រមាប់= ក. កំប្លែង, ធ្វើឬកពាដូចស្វា ។

ឱវាទ= (ម.ថ.អោ-វ៉ាត) ន. ដំបូន្មាន, អនុសាសន៍ ។

បរិស័ទ្ធ-ស័ទ្ធ= (ម.ថ.បរិសត) ន. ពួកជនដែលប្រជុំ

គ្នា, ពួកជនដែលស្នេហ៍គ្នារួមគំនិតមកស្លាប់ជូលគ្នា ។

មិនញ្ជោប= ក. មិនខុនដោយអាការញ្ជើត ។

ខ. អក្ខរាវិរុទ្ធ

ព្រៃបៗ = គុ. ឬ ក. វិ. ដែលស្រក់ប៉ុនរឿយ ។ (ក្ងែងរលឹមព្រៃបៗ) ។

ព្រៃប = ក. ពាសទឹងក្បាល, ជាន់ទឹងដើង, បាក់ទឹងក្អូតដោយពេញកំឡាំង (ដំរី ព្រៃប) ។

ព្រៃប = ន. ឈ្មោះជូសរឹមួយយ៉ាង (ជូសរឹព្រៃប) ។

ភ្លៃប = ក. ចាំមិនចាន (ក្មេចមេរៀន) ។

មិប =ក. ប៉ប្រិចភ្នែកជាសញ្ញា (មិចភ្នែកឲ្យគេ) ។

មិប ក. = បិចយ៉ាងឆ្ងន់ដៃ (មិចថ្ពាល់ក្មួនក្មេង) ។

ម៉ែបជូម្ដែប= ន. អ្វី, យ៉ាងណា (យ៉ាងម៉េចគេ?)

ម្រែប = ន. ឈ្មោះដំណាំមួយយ៉ាង (ដើមម្រែច) ។

រែប = គុ. ដែលស្មុះបន្តិច ។ (សំពត់រេចជាយ) ។

លំប = ក. ចូលចេកបំបាត់ភ្លៅ (ទូកលិច; ថ្ងៃលិច) ។

លិំប = (ម. ថ. ឡិច) ន. ឈ្មោះទិសដែលព្រះអាទិត្យអស្តង្គត (ទិសខាងលិច) ។

លែប = ក. ចេញពីទីកំបាំង (ស្រាប់តែយើញរលេចផ្ទឹមពីក្នុងដែព្រមក) ។

លែប = ក. ជ្រាបហូរចេញ (ទឹករលេចពីភ្លឺស្រែ) ។

លែប = ក. រៀនចេញ (គ្រាប់ឈើដុះលេចពន្លកពីក្នុងដី) ។

លែប = ក. ផ្សាយចេញ (លេចដំណឹង, លេចសំដី) ។

លែប = ក. បង្ហាញមុខឲ្យយើញ (ប៉ុះទើបនឹងលេច

ម្ខុរមកពីណាហ្នឹង ?) ។

លៀប= គុ. ដែលមិនតត់ (ផ្ទះលៀប, ពាងលៀប) ។

លៀប= ន. ឈ្មោះដំបៅមួយយ៉ាង (ដំបៅលៀប) ។

វិប= កិ. ស្បាញ្ជ្រែទ្បាប់ប្ដូងក្លិតមុខបូលមកវិញ (វិចជាយ កន្ទុល) ។

វិបៗ= កិ.វិ. ដែលបក់រឿយៗ (គោបក់កន្ទុយវិបៗ) ។

រៀប= កិ. ធ្វើឲ្យជាបង្វែច (រៀបសំពាយ, រៀបចាយសំណុំ)។

២៦. កែវភ្នែកនឹងកែវប្រាជ្ញា

ពន្លឺកែវភ្នែកយើងដែលភ្លឺនោះ មិនមែនភ្លឺតាមទំនើងខ្លួន

ឯងតែម្យ៉ាងទេ គេងអាស្រ័យពន្លឺខាងក្រៅផង បើមានតែ
កែវភ្នែកមិនមានពន្លឺថ្ងៃនឹងពន្លឺភ្លើងខាងក្រៅជាជំនួយផងទេ ក៏
មិនអាចនឹងមើលឃើញរូបពងអ្វីឲ្យជាក់ច្បាស់បានដែរ ឬថា
មានតែពន្លឺខាងក្រៅមិនមានពន្លឺភ្នែកផង ក៏មិនអាចនឹងឃើញ
នូវតម្កាងពួងបានដែរ ពន្លឺកែវភ្នែកនឹងពន្លឺខាងក្រៅត្រូវអា-
ស្រ័យគ្នាទៅវិញទៅមកជាធម្មតាទើបសម្រេចកិច្ចទៅបាន ។
ចំណែកកែវប្រាជ្ញាយើងក៏ដូចកែវភ្នែកដែរ បើមានតែ
ពន្លឺកែវប្រាជ្ញាខាងក្នុងប៉ុណ្ណោះ ឥតមានពន្លឺខាងក្រៅជាជំនួយ
ទេ ក៏មិនអាចនឹងដឹងការខ្លះត្រូវស្មុះស្មៃក្នុងបានទេឬ គឺថាបើ
មានតែប្រាជ្ញាម្នាក់ឯងមិនមានវិជ្ជាជាជំនួយ ទៅផ្គប់ជាជញ្ជាំង
កញ្ចក់ផងទេ ក៏មិនអាចនឹងឆ្លុះឲ្យដឹងការខ្លះត្រូវឬការអ្វីសព្វ
ចំពូកទៅបាន ឬថាបើមានសុទ្ធតែក្បួនខ្នាតយ៉ាងប្រើនដំកល់

ធ្លាក់ចិត្តចំពោះការសិក្សា តែមិនយកកែវគឺបញ្ញាខ្ចីទៅរៀនសូត្រ
ពិចារណាការពិសោធន៍ថាមានប្រយោជន៍ឬឥត
ប្រយោជន៍ផងទេ ពន្លឺកែវគឺកម្លាំងខ្លួនទាំង ក៏មិនអាចនឹង
សម្រេចប្រយោជន៍អ្វីបានឡើយ ។

តក. ពាក្យពន្យល់

ប្រាជ្ញា= (ម.ថ.ប្រាជ្ញា) ន. សេចក្តីដឹងច្បាស់;
ដឹងដែលកើតអំពីការរៀន, ស្តាប់, គិត; ការដឹងច្បាស់ឬ
សេចក្តីពិត (intelligence) ។

ពន្លឺ= ន. សភាវៈដែលភ្លឺ; វត្ថុដែលភ្លឺ ។

កែវភ្នែក= ន. វត្ថុដ៏ថ្លាស្អាតដែលនៅបំពាក់កណ្តាលនៃ
ភ្នែក ។

ស្មូម= ន. សេចក្តីសប្បាយ; សេចក្តីសម្រាន្ត; ដំណើរ
ស្រណុក ។

ទុក្ខ= (ម.ប.ទុក) ន. សេចក្តីព្រួយ; សេចក្តីលំបាក (កាយ ឧ ធ ប ត្ត) ។

រុជ្ឈ= ន. (ម.ព.កង់អត្ថបទលេខ១) ។

ផ្តប់= ក. ទប់ឲ្យនឹង; កត់ទប់ឲ្យនៅនឹង) ។

កញ្ចក់= ន. កែវសម្រាប់ដុះស្រមោល ។

សព្វបំពុក= គុ. គ្រប់មុខគ្រប់យ៉ាង ។

បញ្ញាបក= ន. (ម.ព.កង់អត្ថបទលេខ១៤ ។

១. អក្ខរាវុន្ធ

អំពីស្រៈ: —+ បន៏ងស្រៈ: អ + ប់

អ្នកអានប្រឹនតែអានសំឡេងនេះដូចគ្នា, ឧទ. គុប្ប នឹង គុប្ប គឺអានស្រដៀងគ្នា ។ ដូច្នេះ នាំឲ្យអ្នកសរសេរពាក្យកំណត់ចំណាស់ៗ តែត្រូវសង្កេតវិធីយ៉ាងងាយដូចតទៅនេះ:

បំពោះវ្យញ្ជន: "គ" គ្មានប្រើពាក្យ "គុប" គ + ុ + ប) ឧទ្ធរណ៍

"ឃ" ពាក្យតម្រូវ "ឃ្ល" គ្មានប្រើពាក្យ "ឃ្លប់" (ឃ + ្ល + ប + ់) យ៉ាងនេះឧទ្ធរណ៍

"ង" គ្មានប្រើពាក្យ "ង្គុប" (ង + ្ + គ + ុ + ប) ឧទ្ធរណ៍

"ជ" គ្មានប្រើពាក្យ "ជ្ជុប" (ជ + ្ + ជ + ុ + ប) ឧទ្ធរណ៍

"ឈ" " "ឈ្ឈុប (ឈ + ្ + ឈ + ុ + ប) ឧទ្ធរណ៍

"ឈ្ល" " "ឈ្ល្លុប" (ឈ + ្ + ល + ្ + ល + ុ + ប) ឧទ្ធរណ៍

"ឈ" " "ឈ្ឈុប" (ឈ + ្ + ឈ + ុ + ប) ឧទ្ធរណ៍

"ទ" " "ទ្ទុប" (ទ + ្ + ទ + ុ + ប) ឧទ្ធរណ៍

សង្កេត.- វ្យញ្ជន: "ទ + ្" នេះ, បើជាពាក្យបាលីឬសំស្ក្រឹត, គេប្រើ ទ + ្ តែព្រាហ្មប្រើជាវ្យញ្ជន: "ព" ដូចជា: ទ្ធលាភ, ទ្ធាសិត ។ល។

"ន្ត្រែ" គ្មានប្រើឯកវចនៈ "ន្ត្រែប៉ំ" (ន + ្រ + ែ + ប៉ំ) ឡើយ មានតែពាក្យសំស្ក្រឹត ១ ម៉ាត់គឺ: ន្ត្រៃ តែព្រាហ្មប្តូរឯកវចនៈ

ពហុវចនៈ ។

២៣. ព្រហ្ម ទិដ្ឋ

មនុស្សដែលមានព្រហ្មទិដ្ឋនៅក្នុងខ្លួន បាត់ថាជា
មនុស្សខ្មែរខ្លះសំដៅជាធម្មតាលោកនេះ ទើលោកឯទៀត
ព្រោះបាត់ធម្មតាអ្វី ។ ដែលជាការចង្អៀតកំបាំងទាំងប៉ុន្មាន
ក៏ស្មុនតែជាកំប្លែ ជាអាហារ របស់អ្នកដែលមានព្រហ្មទិដ្ឋ
ទាំងអស់ មិនមែនជាកំប្លែជាអាហារបស់មនុស្សសាមញ្ញ ដែល
ឥតព្រហ្មទិដ្ឋនោះទេ ។ ឯមនុស្សដែលមិនមានយោបល់
ទើបំណែនាំឥរិយាបថក្នុងខ្លួនហើយ កុំថាឡើយមនុស្ស
បែបនោះតែម្នាក់ឯង ក្រែងមិនអាចទទួលធ្លុះធ្លាំងនោះបាន
ទេ បើមានខ្លួនប្រែនពប់រយពប់ពាន់នាក់ក៏ដោយ ក៏មិនអាចទើ
ជានាសម្រេចការដែលក្រេចង្អៀតនោះបានឡើយ ។ ឯការ
ទាំងឡាយអំបាលនោះ ស្មុនតែសំបាប់រង្គាន់របស់អ្នកមាន
ព្រហ្មដំរះទាំងអស់ មនុស្សបែបនេះកុំថាឡើយមានរូបប្រែន
ឆាក់ទើបអាចទទួលទ្រទ្រង់ការក្រេចង្អៀតនោះបាន ដោយ

ហោចទៅសូម្បីតែម្នាក់ឯង ក៏គង់អាចជានារងព័ប់បានពិត ។
មិនខាន ។

ក្រៅពីនិងរឿងទាំងពីរប្រការនេះ ព្រះពុទ្ធដីកាទ្រង់សរ-
សើរថាជាតែរដ៏វិសេស ជាគុណជាតិតែងធ្វើឲ្យសម្រេចនូវ
ប្រយោជន៍គ្រប់យ៉ាងគ្រប់បំពួកបាន ទើងថាជាទ្រព្យដ៏មានដម្លៃ
តែងជាប់ដៃគាន់ទៅមកជាមួយ ទើងខ្លួនក្នុងលោកនេះទើងលោក
ខាងមុខ ។

ក. ពាក្យពន្យល់

បង្អៀត= គុ. ដែលមិនទូលាយ; ដែលជ្រៀតជ្រៀត ។

មនុស្សមាមញ្ញ= មនុស្សឆ្មើងឆ្មៃ; មនុស្សជាន់ឆ្មើងឆ្មៃ ។

ហែហប់= ន. សេចក្តីយល់ឃើញ, ដំណឹងគិតយល់, គំនិត
ឆ្លុះយល់ ។

ប្រការ= ន. (ម. ព. ក្នុងអត្ថបទលេខ ១៦) ។

ឃ្លុះ= ន. ដំណើរដំពាក់ដោយកិច្ចនីមួយ ។

ជាជា= កិ. ទន្ទួលរ៉ាប់រងលើខ្លួន, ទន្ទួលអះអាង ។

អម្បាលនេះ= និ. ទាំងអស់នោះ ។

សំបាប់= ន. ក្តៅដំណែល, របស់ជាដំណែល, មតិក ។

រង្វាន់= ន. របស់ជាបំណាច់ដែលគេឲ្យដល់ជនណាមួយ ដោយសេចក្តីពេញចិត្ត ។

ជ្រែះ= កិ. ធ្វើឲ្យជ្រះ, ធ្វើឲ្យថាប់ស្រេច, កាត់សេចក្តីសាញ ។

ច្រែច្រង់= កិ. ជួយទំនុកបំរុង, កាន់កាប់រក្សា, លើកដំកើង ។

ដោយហេតុនៅ= និ. យ៉ាងនាបំផុត, យ៉ាងល្អិតល្អន់ ។

ពុទ្ធដីកា = (ម.ប. ពុទ្ធ-ធ:ដីកា) ន. ព្រះបន្ទូលរបស់ព្រះពុទ្ធ, ពុទ្ធវចន: គឺបាលីដែលជាគោលដើមនៃព្រះពុទ្ធសាសនា ។

សរសើរ= កិ. និយាយលើក, ពោលពណ៌នាទូន្មគុណ

របស់នរណាម្នាក់, និយាយសើច (admirer) ។

វិសេស= (ម.ថ. វិសេស) គុ. ប្រសើរ, ថ្លៃថ្លា, ខុសឆ្គងពីគេ ។

គុណជាតិ ឬ គុណជាតិ= (ម.ថ. គុណ:ជាត) ន. គុណ

គ្រប់យ៉ាង ។

១. អក្ខរាវិរុទ្ធ

"ង្ហ" គ្មានប្រើពាក្យ "ង្ហប" (ង+ ្ហ+ ុ+ប) ឡើយ ។

"ង" " "ង្គប" (ង+ ្គ+ ុ+ប) ឡើយ ។

"ព៉" " "ព៉ប" (ព+ប+ ៉) ឡើយ ។

មានតែពាក្យប្រើនព្យាង្គ ហើយជាប់ដោយព្យញ្ជន:ដទៃជា

ព្យាង្គខាងដើមផង ដូចជា:

កំពប់, ដីពប់ ។ល។

"ភ" គ្មានប្រើពាក្យ "ភុប" (ភ+ ុ+ប) ឡើយ ។

"យ" គ្មានប្រើពាក្យ "យុប" (យ+ ុ+ប) ឡើយ ។

ព្រលឹងខ្មែរ
www.khmerhumanities.ir

"ព្យ" មានប្រើពាំងពីរបែប, តែមានសេចក្តីសង្កត

ខ្សែតាយ៉ាងនេះ

លប់=ន. ប្រដាប់សម្រាប់ងាក់បក្សី (លលកព្រៃដាប់

លប់; លប់សម្រាប់ដាក់ទា) ។

លុប=គុ. ធ្វើឲ្យបាត់ស្នាម, បំបាត់មិនឲ្យមាន (លុប

អក្សរ, លុបអណ្តូង) ។

លុប=កិ. លាងដំរះដោយទឹក (លុបមុខ, លុបខ្លួន) ។

លុប=កិ. គ្របលើ (សំឡងឮលុបគេទាំងអស់) ។

លុប=គុ. ដែលបំបាត់គុណគេ(មនុស្សលុបគុណគេ)។

ប៉ុន្តែ គេអាចសរសេរជា: "លប់ប៉" (លប់+ប+ ') យ៉ាងនេះក៏

ចុន ។

២៨. ប្រទេសខ្មែរធំជាងលាវបំពោះសម្ព័ន្ធភាព

ខាងទាបាង

សន្ទិសីទទូលអាញ្ញត្តិ ន្ទូវខ្រមត្រៀងស្តីអំពីការ
បញ្ឈប់សង្គ្រាមនៅប្រទេសវៀតណាម ។ តាមន័យខ្រម
ត្រៀងនេះ មិនត្រូវឲ្យមានមូលដ្ឋានទ័ពរបស់រដ្ឋបរទេសណា
អាចតាំងនៅក្នុងតំបន់ទុកឲ្យធ្លុះគ្នា របស់ភាគីទាំងសងខាងបាន
ឡើយ ។ ភាគីទាំងពីរនេះត្រូវមើលងួនថែ កុំឲ្យតំបន់ដែលគេ
បែកឲ្យខ្លួននោះ ចូលក្នុងសម្ព័ន្ធភាពទាហានណាមួយ ហើយ
នឹងកុំឲ្យយកតំបន់នោះប្រើប្រាស់ ដើម្បីបង្កើតសង្គ្រាមជាថ្មី
ឬក៏នឹងបំរើនយោបាយបៀតបៀនឡើយ ។

សន្ទិសីទទូលអាញ្ញត្តិដែរ ន្ទូវសេចក្តីថ្លែងការណ៍នៃ
រដ្ឋកិច្ចាលប្រទេសកម្ពុជា នឹងប្រទេសលាវ តាមសេចក្តីថ្លែង
ការណ៍នេះ ប្រទេសទាំងពីរនឹងមិនត្រូវជាប់ដំណាក់ ដោយកិច្ច
ព្រមព្រៀងណាជាមួយនឹងរដ្ឋទាំងឡាយឯទៀតទេ ។ បើកិច្ច

ព្រមព្រៀងនោះមានការបង្ខំឲ្យប្រូលសម្ពន្ធភាពគាហាន ដែល
មិនស្របទៅតាមគោលការណ៍ទាំងឡាយ នៃធម្មនុញ្ញសហ-
ប្រជាជាតិ, ប្តូចំពោះប្រទេសលាវ ដែលមិនស្របគោល
ការណ៍នៃកិច្ចព្រមព្រៀង អំពីបទបញ្ឈប់សង្គ្រាមទាំងឡាយ
នៅប្រទេសនេះ, ប្តូជាពិសេសន្ធិភាពរបស់ខ្លួន មិនទាន់
សត្រូវមកគំរាម ជាពិនោះមិនអាចឲ្យមានមូលដ្ឋានច្បាស់
ទេសមកតាំងនៅលើដែនដីខ្លួនទឹងដែនដីលាវបានឡើយ ។

ក. ពាក្យពន្យល់

សម្ពន្ធភាព= (ម.ថ.សម-ព័ន-ធ:ភាព) ន. ភាពនៃការតាក់
តងរកគ្នានៅវិញនៅមក ។

សន្ធិសីទ= (ម.ថ.សន់-និសីត) ន. ការប្រជុំគ្នាដោយដំណើរ
ការ ។

អគ្គិយយ៉ាងស្ងាត់ស្ងៀម ។

អាញ្ញត្តិ= (ម.ថ.អាញ៉ាត) ន. សេចក្តីបង្គាប់; ពាក្យបង្គាប់;

ឧបគ្គាប់ ។

ជំងឺ=(ម.ប.នែ)ន. ការពិណនាំ; សេចក្តីពន្យល់ ។

ជួលដាច=(ម.ភ. កង្ខអត្ថបទលេខ ១ ៤០) ។

ប្រទេស=(ម.ប.ប-រ:-) ន. ប្រទេសក្រៅ; ប្រទេសដទៃ (étranger) ។

ផ្ទឹក្សា=ក. ប្រមូលគ្នាឲ្យជាដុំ; ប្រជុំគ្នាជាដុំ ។

ភាគី=ន. (ម.ភ.កង្ខអត្ថបទលេខ ១ ៤០) ។

ឆ្កែនបៃ=ក. ស្ងួនរកឮទុក; ថែរក្សាពុំឲ្យរង្គាយ ។

សង្គ្រាម=(ម.ប.សង្គ្រាម) ន. បំបាំង ។

ឧបយោគយ=(ម.ភ. កង្ខអត្ថបទលេខ ១ ៤៨) ។

សេចក្តីប្តឹងការណ៍=ន. សេចក្តីប្រកាសឲ្យ; សេចក្តីឲ្យដំណឹងជាសាធារណៈ ។

រដ្ឋាភិបាល = (ម. ថ. រ៉ត់..ហ៊ា-) ន. (ម. ព. កឝ្ឍអត្ថបទ ៤ ១ លេខ ៣៩) ។

គោលការណ៍ = ន. ខ្សែចក្តី, ហេតុដែលជាគោលចាំក; កស្តុតាងនៃច្បាប់ ។

ធម្មនុញ្ញ ឬ ធម្មនុញ្ញ = (ម.ថ. —ឆ័ម-ម: នុញ្ញ, —នុញ្ញ) ន. ឈ្មោះច្បាប់មួយក្រម សំដែងអំពីរបៀបតុលាការ ។

សហប្រជាជាតិ = (ម. ថ. ស:ហ:—) ន. ជាតិផ្សេងៗ គ្នាដែលរួបរួមកិច្ចព្រមព្រៀងជាមួយគ្នា ។

សន្ធិភាព = (ម. ថ. សន់—ធិ—) ន. ភាពឬដំណើរស្ងប់ សាន្តត្រាណ រាបទាប; ដំណើរសះជានឹងគ្នា ។

១. អក្ខរាវុន្ធ

អំពីស្រៈ ◌ + ◌ ង ទីង ស្រៈ អ + ◌ ង

"គ" គ្មានប្រើពាក្យ គុង (គ + ◌ + ង) ឡើយ ។

"គាំង" គប្បីសរសេរជា: " គ + ◌ំ + រ + ង + ◌ ' "

យ៉ាងនេះតែម្យ៉ាង ។

" ឃ្ល " គ្មានប្រើពាក្យ " ឃ្លុង " (ឃ + ◌ ្ល + ◌ + ង) ឡើយ ។

" ជ " គ្មានប្រើពាក្យ " ជុង " (ជ + ◌ + ង) ឡើយ ។

" ជង្ឃង " គប្បីសរសេរជា: " ជ + ◌ + ◌ ្ឃ + ង + ◌ ' " យ៉ាងនេះតែម្យ៉ាង ។

" ញ្ញ: ញង " គប្បីសរសេរជា: " ញ + ◌ + ◌ ះ + ញ + ង + ◌ ' " យ៉ាងនេះតែម្យ៉ាង ។

" ឲ " មានប្រើតាំងពីរបៃបៃ, តែមានសេចក្តីសង្កត្តខ្លួន

គ្នាយ៉ាងនេះ

ទ្រង់= ន. ផ្ទាំងសំពត់ឬក្រដាស ដែលមានពណ៌ឬរូប
ផ្សេង ។ សម្រាប់ប្រើជាកិត្តិយសក្នុងប្រទេសមួយ ។: ទង់
ជាតិ, ទង់សាសនា, ទង់ខ្មោច, ទង់ជ័យ ។

ពាក្យពីសេសដែលជាប់ដោយទង់

ទង្គិត់, ទង់ដែង, ទង់ហ្វាំ ។

ទ្រង់= ន. ឈ្មោះបក្សីមួយយ៉ាង: សត្វទុង ។

ទ្រង់ឬទ្រូង= ឧ. សូរអ៊ីនមួយដែលឮខ្លាំង: ភាំក្អើងឮញាញ
ឮសូរទុង ។

២៩. សេចក្តីសប្បុរស

ខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា តែងប្រដៅកូនចៅឲ្យកាន់
បត្តសប្បុរសនឹងលោកសង្ឃ នឹងសមយាចក ហើយអាណាត
មេត្តាដល់អ្នកកំសត់ទុគ៌តគោកយ៉ាកលំបាកផង ។ ហេតុដូច្នេះ
បានជាគេឃើញខ្មែរ ឲ្យទានធ្វើបុណ្យជារឿយ ។ កឋិនវត្តអា-
រាម ហើយគេជួយមនុស្សក្រីក្រគោកយ៉ាកលំបាក ឲ្យមានអា-
ហារបិណ្ឌបាតជីវិត ហើយនឹងសម្លៀកបំពាក់ល្អមសមគួរផង ។
ខ្មែរតែងតែដឹងលមនុស្សណា ដែលមានបត្តជាអសប្បុរស
អកតញ្ញូនឹងអ្នកដ៏មានគុណ មានមាតាបិតាគ្រូអាចារ្យ ហើយ
នឹងអ្នកដែលជួយទំនុកបំរុងផងដែរ ឲ្យបានប្រយោជន៍ផង ។
ជាដើម ។ គេមិនរាប់អានមនុស្សដូច្នេះទេ ហើយគេស្អប់ហើយ
គេមិនឃេកជាមិត្រសំឡាញ់ទេ ។

ទោះជាមានសេចក្តីចំណេញប្រកបដោយធម៌ដូច្នេះ ក៏
គង់នៅមានមនុស្សខ្លះមានបត្តកំណាញ់ ។ មនុស្សខ្លះមិន

ដែលធ្វើបុណ្យឲ្យទានសោះ ហើយកំណាញ់ទឹងខ្លួនឯងផង ។

ក. ពាក្យពន្យល់

សេចក្តីសប្បុរស= (ម.ថ.សប់-ប៉ុរ៉ស់) ន. សេចក្តីល្អដែល
ធ្វើដោយការអាណិតចិត្ត (charité) ។

ពុទ្ធសាសនា= (ម.ថ.ពុត-ធ:-) ន. ពាក្យប្រៀនប្រដៅរបស់
ព្រះពុទ្ធ (religion bouddhique) ។

លោកសង្ឃ= ន. អ្នកបួសក្នុងព្រះពុទ្ធសាសនា ។

សុមរៀបចក= (ម.ថ.-យោចក់) ន. អ្នកសូមទានដែលក្រីក្រ
ល្អំបាកគេគេចយ៉ាក ។

ទុគ៌ត= (ម.ថ. ទុគ៌ត់) គុ. ដែលជួនវេសចក្តីលំបាក; ដែល
ក្រីក្រខ្លាំង, ដែលទីឥតល់ក្រ ។

វិត្ត= (ម.ថ.វ៉ិត់) ន. អារាមសម្រាប់នៅអាស្រ័យរបស់ពួកសមណៈ

អារាម= (ម.ថ.- ព៉ាម) ន. ប្រទេសឬទីដែលនាំទឹកចិត្តឲ្យរីក-

វាយសម្បាយ; (ក្នុងទីនេះ) សំដៅសេចក្តីថា វត្ត ។

ត្បុះត្បែងដៀលៗ= ក. និយាយបង្អាប់បន្ទះដោយបញ្ចេះបញ្ចោសអំពី

ទោសដែលខ្លួនមាន ។

អ្នសប្បុរស=(ម.ថ អ:សប់-ប៉ុរ៉ាស់) (ក្នុងទីនេះដា គុ.) ដែលមានចិត្តអាក្រក់, ដែលអាក្រក់ ។

អ្នកឆ្លាត=(ម.ថ.អ:ក:ឆ័ញ-ញ្ញ)ន. (ក្នុងទីនេះដា គុ.) ដែលស្ទើសគុណ; ដែលមិនដឹងឧបការគុណដែលគេបានធ្វើហើយ (ចំពោះខ្លួន) ។

គ្រូអាចារ្យ=ន. គ្រូដែលជាអ្នកប្រៀនប្រដៅ បង្វឹកបង្វឺនគំនិតមារយោគឲ្យបានត្រឹមត្រូវល្អ ។

សេចក្តីទូន្មាន= ន. សេចក្តីប្រៀនប្រដៅ (conseil) ។

កំពាត្បាត= (ក្នុងទីនេះដា កិ.) រំនិសិតស្វាញក្នុងការចាយវាយ ។

១. អក្ខរាវិរុទ្ធ

"ទំរង់" គប្បីសរសេរជា: "ទ + ◌ំ + រ + ◌ង + ◌់ "

យ៉ាងនេះតែម្យ៉ាង ។

"ទ្រ", មានប្រើទាំងឥរយ៉ាង, ប៉ុន្តែមានសេចក្តីសង្កេតខុសគ្នា

យ៉ាងនេះ

ទ្រង់= ភា. ប្រព្រឹត្ត, ការ: ព្រះសង្ឃទ្រង់ធម៌; ស្តេចទ្រង់ព្រះ

ពស្ត្រសៈ, លោកសង្ឃទ្រង់ចីវរ ។

ទ្រង់= បុ. ស. (រ. ស.) ព្រះអង្គ (សូមទ្រង់ទ្រាស្រព្រះរាជទាន

អភ័យគោស) ។

ទ្រង់= ន. ទំរង់, សណ្ឋាន, លំនាំ, ពង, រូប(តុនេះមាន

សណ្ឋានទ្រង់ទ្រាយកូរឲ្យស្រឡាញ់) ។

ទ្រុង= ន. ប្រដាប់សម្រាប់ដាក់សត្វ: ទ្រុងមាន់, ទ្រុងខ្លា,

ទ្រុងត្រី ។

"ផ្ដាំ" គឬ៎សរសេរជា "ផ+ ាំ+ ' " យ៉ាងនេះតែម្យ៉ាង ។

"ផ្ដាំ" (ឆ្នូតត្រី) គឬ៎សរសេរជា: "ផ+ + ាំ" យ៉ាងនេះ
តែម្យ៉ាង ។

"ផ្ដាំ" (បញ្ចូលឆ្នូត, ខ្សែបឆ្នូត, ម៉ើលទៅឃើញឆ្នូត) គឬ៎
សរសេរជា: (ផ+ + +ាំ) យ៉ាងនេះតែម្យ៉ាង ។

"ផ្ដាំ" (ផ្កដ់ចង្ហាន់, ផ្កដ់គ្រឿងប្រើប្រាស់) គឬ៎សរសេរ
ជា: "ផ+ ាំ+ ' " យ៉ាងនេះតែម្យ៉ាង ។

"ព" មានប្រើពាំងពីរយ៉ាង, ប៉ុន្តែមានសេចក្តីសង្កេតខ្សែ
គួរយ៉ាងនេះ

ពង់= កិ. បំពេញ, បំអែង: ក្រុងពង់ ។

ពង់= កិ. ដោះរាល់គ្នាទៅវិញ: ពង់ខ្លះ ។

ពង់= កិ. (ន.ប្រ.) ក្រែអែត ក្រអោង: ចូកពង់ ។

ពុង= ប. ពាក្យសម្រាប់និយាយផ្សំនឹងពាក្យពោះ: ពោះពុង ។

ពុង= ន. ពោះ: ម្ដាយមានពុង, ពេលគាត់នៅផ្ទះ, គាត់ចោមពុង ។

ខែពុង= ខែដែលចាំបាច់តែពោះសត្វ ។

៣០. សមាធិ

ចិត្តាជាវលេកថាមពលេ ដែលញាប់ញ័រចេញទៅក្នុង

សរីរកាយ ប្រកាសចេញទៅត្រូវជាអំពើចិត្តា នឹងមានកម្លាំង

ខ្លាំងប្លែកឡូយស្រេចហើយនឹងការគិត បើគិតរវើរវាយ ចិត្តា

ពុំមានកម្លាំងល្មមនឹងសំដែងឲ្យយើញប្រចក្សទេ បើគិតតែពី

ចិត្តានោះដោយយកចិត្តទុកដាក់ ទើបចិត្តានោះប្រកបដោយ

កម្លាំងខ្លាំង។ ដែលញ៉ាំងចិត្តឲ្យខ្ចែងរែងល្អគឺសមាធិ ។

សមាធិគឺការដំរង់កម្លាំងចិត្ត សំដៅចំពោះចំណុចណាមួយ

ដោយមិនរវើរវាយ ឬងាកទៅរកអារម្មណ៍ ឬហេតុការណ៍ដទៃ

ដែលគ្រាកជានៅទីជិតខាងនោះ ។ កែវឆ្នុះដែលទាញរស្មីព្រះ

អាទិត្យ ប្រមូលធ្នុំទៅលើក្រដាសមួយសន្លឹក ក្រដាសនោះក៏

ឆេះ មានសេចក្តីយ៉ាងណាមិញ ឯការប្រមូលកម្លាំងចិត្តធ្នុំទៅ

ក្នុងអារម្មណ៍តែមួយ អាចឲ្យចេញពន្លឺបានក៏យ៉ាងនោះដែរ ។

ដូច្នេះ ការតាំងចិត្តជាសមាធិនាំឲ្យងាយដោះស្រាយនូវប្រស្នា

ផ្សេង ។ ឬគិតការអ្វីមួយបានដោយឆាប់រហ័ស ឬបេះចាត់
ការបានភ្លាម ។ ឬធ្វើកិច្ចការទាំងឆ្ការយបានដោយរហ័ស
ហើយល្អផង ។ សមាធិចិត្តជាលក្ខណៈនៃជនជាឯតទគ្គ
បុគ្គល ។

ក. ពាក្យពន្យល់

សមាធិ= (ម.ថ. ស:ម៉ា-ធិ) ន. ដំណើរស្ងប់ចិត្តស៊ប់
ក្នុងអង្គឈាន, ការប្រុងប្រយ័ត្នស្ងប់ចិត្តក្នុងគន្ថធម៌
រម្ងាប់ដែលរំពឹង, ការនឹកពិចារណាស្ងប់ចិត្ត ។

ចិត្ត= (ម.ថ.ចិន-ដា) ន. សេចក្តីគិត, គំនិត (Pensé)

ចាមពស= (ម.ថ. ចាម:ពស់) ន. កំទ្រាំងពស់ ។

សរីរក្ខាយ= (ម.ថ. ស:រ៉ី:-) ន. រូបកាយទាំងស្រុង,
ខ្លួនប្រាណ; កម្រងនៃរូប ។

ប្រកាស= កិ. ថ្លែង, សំដែងប្រាប់ឲ្យដឹង ។

ព្រះមឹងខ្មែរ
www.samnangkhmer.net

ប្រែបក្ស= (ម.ព.កង្ខអត្ថបទលេខ ៣) ។

ខែងវែង= (ម.ព.កង្ខអត្ថបទលេខ ៤០) ។

អារម្ម៉ណ៍= (ម.ព.កង្ខអត្ថបទលេខ ៤១) ។

វស្ស= (ម.ព.កង្ខអត្ថបទលេខ ១៣) ។

ប្រែស្ប= ន. ចំណែក, សេចក្តីអាថ៌កំបាំងផ្សេង ។

សមាធិប៊ិត្ត= ចិត្តដែលមិនរវើរវាយ, ចិត្តដែលស៊ប់ស្ងួន ។

ឯតទគ្គបុគ្គល= (ម.ថ.អេត:ទ័ក-គ:បុកគល់)

ន. បុគ្គលឬបុរសដែលគេលើកថាលើសលែងឬប្រសើរ

ជាងគេខាងមុខការឬបំណែងវិជ្ជាណាមួយ ។

ឲ. អក្សរកាវ៉ុន្ធ

"ព្រែង" (វន្ទឈើឬវន្ទសត្វ: ព្រង់ជាស) គឬសរសេរ

ជា: "ព + ្រ + ែង + ') យ៉ាងនេះតែមក៏ផង ។

"ភ្ជុំ" (ស្បូរពួរដោយឆ្អាយ ឬមែកឆ្កឹងទឹកជារដើម) គប្បី

សរសេរជា: "ភ្ជ + ុ + ំ" យ៉ាងនេះតែម្យ៉ាង ។

"ភ្ជុំ" (ឆ្អាក់ក្នុងទឹកឮស្បូរក្ងួង) គប្បីសរសេរជា: "ភ្ជ + ុ + ំ" យ៉ាងនេះតែម្យ៉ាង ។

"មមុំ" (សត្វមមង់នៅក្នុងផ្ទៃល្ហា) គប្បីសរសេរជា: "ម + ម + ុ + ំ" យ៉ាងនេះតែម្យ៉ាង ។

"ម្ពុំ" (ដេកក្នុងម្មង) គប្បីសរសេរជា: "ម្ព + ុ + ំ" យ៉ាងនេះតែម្យ៉ាង ។

"យ្យុំ" (ហូរយង់) គប្បីសរសេរជា: "យ្យ + ុ + ំ" យ៉ាងនេះតែម្យ៉ាង ។

សន្ថែន.-យ្យ + ុ + ំ គ្មានប្រើឡើយ ។

ទោះបីពាក្យពីរព្យាង្គក៏ដោយ ប្រើតែ យ + ុ + ំ តាំងអស់ តែ

បំពោះតែព្យញ្ជន: (យ) នៅខាងដើម ដូចជា យង់ឃ្នង
យង យល ។ល។

បើព្យញ្ជន: "យ" នៅខាងបុងរហើយជាពាក្យពីរព្យាង្គ
នោះមានសរសេរជា "យង់" ខ្លះ "យុង" ខ្លះ ដូចជា:

ប្លាយង់ = សរសេរនឹង "យង់" ។

ត្រយុង = " "យុង" ។

៣១. សង្ខិត្តសាសនា

ភពនេះ មានសាស្ដាចារ្យជាច្រើន ដែលជា
អ្នកបង្កើតលទ្ធិសាសនាផ្សេងៗ មានពុទ្ធសាសនា, ព្រាហ្មញ្ញ-
សាសនាជាដើម ។ បណ្ដាសាស្ដាចារ្យទាំង
អម្បាលនោះ, ព្រះបរមគោតមបរមសាស្ដា ជាអ្នកបង្កើតលទ្ធិ
ពុទ្ធសាសនា ។ ពួកយើងជាពុទ្ធបរិស័ទបានដឹងច្បាស់ហើយ
ថាព្រះពុទ្ធជាម្ចាស់មិនយល់ព្រមថា មានអាត្មាទេពមានបុគ្គ
ណាមួយ អាចបង្កើតផែនដីនឹងសត្វលោកនោះទេ ។ ព្រះ
អង្គពិចារណាឃើញច្បាប់ធម្មជាតិរបស់មនុស្សសត្វលើផែន
ដីនេះ ស្មុគស្មាញនៅក្នុងវិបរិណាមធម៌ ប្រកបដោយទុក្ខ
លំបាកគ្រប់យ៉ាង, មិនបីតែនៅជាស្ថាពរតាមប្រក្រតី នឹងមិន
លុះកង់រំណាចរបស់ខ្លួន, មានសភាពសោះសូន្យទេ ។
ព្រះពុទ្ធជាស់តឿនឱ្យសត្វលោកពិចារណា សេចក្ដីទុក្ខ
គ្រប់គ្នា កុំធ្វេសប្រហែសថ្លៅលោកព្យាបាទកឿងបង្កវិវេទវេង

មនុស្សលោកឬសត្វជាតុំធំពួង ។ ត្រូវប្រព្រឹត្តធម៌ជាកុ-
សលទឹងមានមេត្តាចិត្តស្រឡាញ់រាប់អានគ្នាទៅវិញទៅមក ។
ក្នុងប្រវត្តិសាស្ត្រ បានបង្ហាញឲ្យយើញកសុតាងស្រាប់ថា តាំង
ពី ២.៥០០ តំមកហើយ តុំមានការបង្ហូរឈាមណាមួយដោយ
យកនាមព្រះពុទ្ធថា ជាអ្នកដឹកនាំនោះឡើយ. ។

ក. ពាក្យពន្យល់

លទ្ធិ= (ម. ព. ក្នុងអត្ថបទលេខ ៣៧) ។

ពុទ្ធសាសនា= (ម. ព. ក្នុងអត្ថបទលេខ ៤៩) ។

ពិភពលោក= (ម. ព. ក្នុងអត្ថបទលេខ ៤៤) ។

សាស្ត្រាចារ្យ= (ម. ថ.-ចារ) ន. អាចារ្យជាអ្នកដឹក
នាំខាងលទ្ធិសាសនា ។

ព្រហ្មញ្ញសាសនា= (ម. ថ. ព្រំម្ញ-ញ: សា.-ស្នា)

ន. សាសនាដែលជាប់ខាក់ខងដោយសេចក្តីប្រកាន់ជឿថា

មហាព្រហ្ម ជាអ្នកបង្កើតពពួកសត្វ, សាសនារបស់ពួក
ព្រាហ្មណ៍ (Religion brahmanique) ។

គ្រិស្តសាសនា= (ម. ថ. គ្រិស-សាស្ន) សាសនា
របស់ព្រះគ្រិស្ត Réligion chrétienne ។

បរមគោតម= (ម. ថ. បរ៉ុម-គោ-ដំ) ព្រះបរមនាម
នៃព្រះអរហំសម្មាសម្ពុទ្ធ ។

ពុទ្ធបរិស័ទ= (ម. ថ. ពុ៉ត-ធ បរ៉ិសត) ន. អ្នកកាន
សាសនាព្រះពុទ្ធ ។

អាទិទេព= ន. ទេវតាដែលជាអ្នកសាងលោក(Dieu) ។

ឥន្ទ្រ= (ម. ថ ឥ៉ត) ន. តេជះ, អំណាច, សេចក្តីអង់អាច ។

សត្វលោក= (ម. ថ. សាត-) ន. ពពួកមនុស្ស
សត្វដែលអាស្រ័យនៅលើផែនដី ។

ជីវាភាព= (ម. ៣. ភូ៉ឆអត្ថបទសេ ១) ។

វិបរីតភាវធម៌= (ម. ថ. វិប៉ៈរុ្ណាភ ម.ឆ័រ)ន. ធម៌
ប្រែប្រួល, សភាវៈផ្លាស់ប្រែ, ដំណើរមិនទៀង ។

ស្ពាយ= គុ. មាំមួន, រឹងប៉ឹង, ជិតដៃ, ខាប់ខ្ជួន ។

ស្រអាក= ក. ស្ងួតបង់បាន, ស្រុកាដោយដំពាក់ចិត្ត

ស្រាយចូន= ក. គូសបន្ទាត់, បង្គំនូរ ។

ស្រីចូន= ន. ដង្កូវ, ដំណើរទាស់នៃឯកតា ។

ហ. អក្សរ ហ

"ហ" មានប្រើតាំងពីរបៃបមកម៉្លេះមានសេចក្តីសង្កេតខ្លះ
គួរយ៉ាងនេះ

ហែ= ក. បង្ហូរចាំ (រង់ចាំទ្រូបន្ទូបសិនណា !) ។

ហង់ជើង= ន. ឈ្មោះរោគពិសម្លួយយ៉ាង ។

ហង្គ= (ម.ថ.រង់) ន. ដំរាមនសម្បុរលឿងសម្រាប់ធ្វើជា

ជាំ : ជ័រវច្ឆិ ។

រុំរ៉ែ= ប្រើនតែប្រើជាមួយនឹងពាក្យខាងបុងខ្មែតដូចជា រុងរឿងរុងរឿងរោចរ៉ែ, រុងរ៉ាងៗលៗ

"លៃ" មានប្រើទាំងពីរវែចម ប៉ុន្តែមានសេចក្តីសង្កត់ខុសគ្នាយ៉ាងនេះ ។

លង់= ក. ជ្រួល, ស៊ុន, ហួស (លង់គំនិត) ។

លង់= ក. លេចកងទឹក: លង់ទឹក ។

លង់= គុ. យូរពេក: យូរលង់ ។

ពាក្យពិសេសដែលប្រើជាប់ដោយពាក្យ លង់ លង់ទ្រេ-ឆេស, លង់លុះ លង់ហិន, លង្វែក ។លៗ

"លង្វង់" (ទ្វាយលន្ទង់លន្ទាប) គឺប្រឺសារសេរជា: (ល+ង+ ្ +ង+ ់) យ៉ាងនេះតែម្យ៉ាង ។

លុង = កិ. ជីកឲ្យកើតជារូង: លុងដី, លុងឈើ, ជីកលុង ។



៣២. ធម្មជាតិរបស់មនុស្ស

ព្រះពុទ្ធបានទ្រង់ព្រះតម្រិះថា មនុស្សហើយរកតែឃើញថា អា-
ការៈក្នុងខ្លួនសុទ្ធតែជាបុគ្គល ។ ព្រះអង្គបានយកបុគ្គលនោះ
ធ្វើជាគ្រឿងពិនិត្យរកសេចក្តីពិត ។ ទ្រង់ចេញជាធាតុមាន
បួន អាការៈធំៗ ដូចជាដីធំជាដើម ហៅថាធាតុដី; អាការៈ
ដែលទន់ភ្លន់ៗ ដូចជាទឹកមាត់ ស្លេសជាដើម ហៅថាធាតុទឹក;
អាការៈដែលក្តៅខ្លាំងៗ ហៅថាធាតុភ្លើង; ខ្យល់ដង្ហើមចេញ
ចូលហៅថាធាតុខ្យល់ ។ កងពលកាយរបស់បុគ្គល មានអា-
ការៈ, សម្ផស្សនិងសម្បជញ្ញៈ ។ ក្រៅពីនោះមានប្រតិកម្មរបស់
វិញ្ញាណដែលផ្គាប់តែទទួលយកនូវអារម្មណ៍ទាំងឡាយ ហើយ
បញ្ជូនទៅឯទ្វារក្បាល ។ បន្ទាប់ពីនោះមកមានសង្ខារ
គឺការស្មុគស្មាញទាំងឡាយ ដែលប្រមូលផ្តុំនៅកងខ្លួន និង
ដួងព្រលឹង មានតណ្ហា, ម្នោរការ, និន្នាការនឹងគំនិតផ្សេងៗ
ជាដើម ។ កងចំណោមសំខារទាំងឡាយនេះ, យើងស្ទួ

ខ្លួនយើងមើល តើមានអ្វីជារបស់ "ខ្លួនយើង" ឬទេ? ព្រះអង្គត្រាស់ថាទេ, ឥតមានអ្វីជារបស់ "ខ្លួនយើង" ទាំងអស់ ។

ក. ពាក្យពន្យល់

ធម្មជាតិ= (ម.ព. ភូតអត្ថបទលេខ ៤០) ។

ជាតុ= (ម.ឋ.ជាត) ន. ដី, ទឹក, ភ្លើង, ខ្យល់, អាកាសហៅថាជាតុ; អាការៈក្នុងខ្លួន ដូចយ៉ាងសក់, ឆ្អឹង, ឈាមជាដើមហៅថាជាតុ ។

បុគ្គល= (ម.ឋ. បុក-គល់) (ក្នុងទីនេះជា គុ.) ដែលគួរពិចារណា, ដែលជារូបសាកសពស្រស់នៃមនុស្ស ។

ពិសោធ= កិ. សាក, ល្បង, លេខើល (essayer) ។

ស្នែស្ន= (ម.ឋ. ស្នែស) ន. ទឹកអំបិលជាប្រភេទដែលចេញមកតាមបំពង់ក ។

សម្ផស្ស= (ម.ថ. សំផស់) ន. ការប៉ះពាល់ត្រូវត្រមែន

អាយតនៈ (sensation) ។

សម្បជញ្ញៈ= (ម.ថ. ស័មប៉ៈជ័ញ ញៈ) ន. សេចក្តីដឹងខ្លួន,

ការគ្រែះរែងដឹងខ្លួនជាដរាប (conscience) ។

ប្រតិកម្ម= (ម.ថ.ប្រ-តិកាំ) ន. ដំណើរដែលតភ្ជាប់គ្នា

(circulation) ។

វិញ្ញាណ= (ម.ថ.វិញ្ញ-ញាន) ន. ធម្មជាតជាគ្រឿងដឹងនូវ

អារម្មណ៍យ៉ាងច្បាស់ ។

សង្ហែរ= (ម.ថ.សង់ខា)ន. គ្រឿងតាក់តែង, សម្ភ័ងកាយ

សុគស្នាញ - គុ. ដែលស្នាញចាក់ស្រែះ ។

តណ្ហា= (ម.ថ. តន់ហា) ន. ចំណង់, សេចក្តីប្រាថ្នា,

(passion) ។

និង្ឃាការ= (ម.ថ. និន-ឃាការ)ន. ការលើកសរសើរ ។

១. អក្ខរាវុឌ្ឍិ

"រ៉ាំង" មានប្រើតែមួយយ៉ាងប៉ុណ្ណោះ ប៉ុន្តែមានសេចក្តី
ផ្សេងគ្នាយ៉ាងនេះ ៖

រ៉ាំង= ក. ធ្វើឲ្យជារង្វង់: វង់ក្អែកក្អាក, ឈរជាំវង់ ។

រ៉ាំង= ន. មណ្ឌលមូល: វង់ចៀន, ក្រុងមួយវង់, ចៀនមួយវង់, វង់ព្រះអាទិត្យ, វង់ក្របក ។

រ៉ាំង= ន. ឈ្មោះល្បែងស៊ីសងមួយយ៉ាង: ក្រុងលេង
គប់វង់ ។

រ៉ាំង្វ= (ម.ច.វង់) ន. ពូជអម្បូរ: ព្រះពជវង្ស ។

៣៣. កម្មដ្ឋានបដិសន្ធិជាដើម

ជនអ្នកកាន់ព្រះសាសនាយល់ឃើញថា សត្វទាំងអស់
នៅលើផែនដី ស្មុគ្មនែត្រូវប្រតិបត្តិតាមច្បាប់មួយ ដែលមិន
អាចលក់ប្តូរផ្លែរទៅអ្នកណាមួយនឹងមិនអាចសាបសូន្យ ឬក៏
ប្រែប្រួលទៅបាន ។ ព្រះពុទ្ធត្រាស់ថា: «បើវត្ថុនេះកើតមាន
ក៏កើតមាននៅមីពីវត្ថុនោះ; ព្រោះតែមានវត្ថុនោះ ទើបមាន
វត្ថុនេះ, បើវត្ថុនោះមិនមាន វត្ថុនេះក៏មិនអាចកើតមានដែរ,
ព្រោះតែវត្ថុនោះវិនាស ទើបវត្ថុនេះរលាយទៅដែរ» ។ នេះ
ជាធម៌មួយនិយាយអំពីកម្ម ។ សៀវភៅធម៌ខាងសាសនាគូ-
លិក មានសរសេរថា «បើអ្នកជាំជំណាំអ្វី, អ្នកនឹងប្រូតយក
ផលជំណាំនោះ» ។ វិទ្យាសាស្ត្រគង់អធិប្បាយថា ហេតុផល
ស្មើនឹងលទ្ធផល, ឯលទ្ធផលផ្ទុយពីហេតុផលទៅវិញ» ។
អំពើណាមួយរបស់មនុស្សព្រោះល្អឬអាក្រក់ក្តី អាចនឹងឲ្យផល
ក្នុងបច្ចុប្បន្ន នឹងអនាគតមិនខាន ។ ឥតមាននរណាមួយ

គេចផុតពីផលកម្មដែលខ្លួនបានធ្វើទៀយ ។ និយាយតាម
ចរិយាសាស្ត្រ, ផលកម្មនេះបង្ហាញឲ្យឃើញការទទួលយក
នូវប្រុណ្យទ័ណ្ឌបាប តាមអំពើល្អទ័ណ្ឌអាក្រក់ដែលយើងបានធ្វើ
ទុកមក ។

ក. ពាក្យពន្យល់

កម្ម = (ម. ថ. ភាំ) ន. អំពើ; កិច្ចការ (action) ។

បដិសន្ធិ = (ម. ថ. ប៉ៈដិសន់ធិ) ន. ដំណកំណើតសត្វ ។

ប្រតិបត្តិ = (ម. ថ. ប្រតិបាត់) កិ. ប្រព្រឹត្ត; ធ្វើតាម ។

សាបសូន្យ = គុ. រសាះសូន្យ ។

វិនាស = ក. អន្តរាយ; បាត់បង់; រលាយ ។

វិទ្យាសាស្ត្រ = (ថ.ម. វិតទ្យា-សាស) ន. វិស្វាឲ្យក
មួយដែលគេរកឃើញដោយការលៃផ្សំ មានការផ្សំធាតុជា
ដើម (science) ។

សេទ្ធដិស = (ម. ព. ក្នុងអត្ថបទលេខ ៦៦) ។

បញ្ញត្ត = (ម. ថ. ប្ញ័ប-ប្ញប-បន់) ន. ពេលដែលតាំង
នៅក្នុងតាលច្ចី ។

បរិយោសាស្ត្រ = (ម. ថ. ចរ:យ៉ោសាស) ន. ក្បួនខ្នាត
ដែលសំដែងអំពីមូលហេតុនៃអំពើល្អ (moralie) ។

ព្រួស.ព្រោះ

ព្រួស= កិ. បង្ហាញទឹកមុខទឹកមាត់ឲ្យខ្លាយដោយកំ-
ណាំងខ្សាច់: ព្រួសទឹក, គ្រាស្ពោះព្រួស ។

ព្រោះ= កិ. ចាបគ្រាប់ពូជដើម្បីឲ្យដុះ (ព្រោះស្រូវ,
ព្រោះគ្រាប់ថ្នាំ) ។

ព្រោះ= អា. និ. ហេតុ, ដ្បិត(រឿងពុំបះព្រោះខ្លួល)។

ព្រៃស - ប្រៃស

ព្រៃស = កិ. (ម. កុស ឬ កុស្ស) ប្រឹងដកកវែស្រែក: ឆ្អែ
ព្រៃសពុំដែលខាំ ។

ប្រៃស= ទ. ស្អប់ដោយដួស, ជ្រាយ, ជ្រាក់, ទជាក់
(ដួសប្រៃស, ជ្រាក់ប្រៃស, ទជាក់ប្រៃស ។) ។

ប្រៃស = ន. ឈ្មោះឈើតែមួយយ៉ាង (ផ្លែប្រៃស) ។
សង្កេត. គេពុំដែលសរសេរ ប្រែះ (ព + ៃ + ះ
+ ៈ) យ៉ាងនេះទេ ។

៣៥. ធម្មជ

អ្វីជាទីដៅរបស់ពុទ្ធសាសនា ? អ្នកកាន់ពុទ្ធសាសនា
បាននឿយថាព្រះនិព្វាន ។ នឿយដូច្នោះពិតជាត្រូវតាមអត្ថ
ជាពិតប្រាកដ ។ ទីបំផុតរបស់ពុទ្ធសាសនាគឺ «ព្រះនិព្វាន»
ព្រោះជាកន្លែងរំលត់ទុក្ខ ជាកន្លែងទេ ទឹងជាកន្លែងបញ្ឈប់
ដំណើរបស់ជាតិ ។ ពួជនៃកិលេសតណ្ហាតូច ។ មាន
អនុស័យកិលេសនឹងកិលេសធំៗ ទាំងឡាយមានពាគ:ពោស:
មោហ:ជាដើម ដែលនាំឲ្យបន្តបន្ទូរជាតិ ជរាព្យាធិនឹងមរណ:ក្នុង
វដ្តសំសារនោះ ឥតមានសេសសល់អ្វីក្នុងព្រះនិព្វាននោះ
ទេ គឺរំលត់សូន្យរេសាះរកនិមិត្តគ្មាន ។ និយាយយ៉ាងខ្លីមកថា
ព្រះនិព្វានជាកន្លែងបញ្ឈប់កំណើតថ្មីរបស់សត្វ ឥតមានជាតិ
ជរាព្យាធិនឹងមរណ: ទេឬយ មានតែបរមសុខតែមួយប៉ុណ្ណោះ ។
ព្រះនិព្វានជាស្ថានសប្បាយនៃព្រះអរិយបុគ្គលទាំងឡាយដែល
ផុតវិស័យរបស់បុថុជ្ជនជឹងបាន ។

ក. ពាក្យពន្យល់

ធំញ្ញែង= (ម.ប. ន៑ម-ញាន) ន. ព្រះធម៌លត់កិលេស, រំលត់បញ្ចក្ខន្ធ ៥ ១៨ គឺលោកុត្តរធម៌ ៩ ១ ដែលកើតអំពីលោកុត្តរៈ ធម៌៨ខាងដើម (មគ្គ ៤, ផល ៤) ។

ពុទ្ធសាសនា= (ម.ព. កង៑អត្ថបទលេខ ៣១) ។

អត្ថ= (ម.ប. អ័ត) ន. សេចក្តី, ពាក្យប្រែស្រាយ ។

ប្រែកដី= (ម.ព. កង៑អត្ថបទលេខ ១១) ។

ជាតិ= (ម.ប. ជាត) ន. កំណើត ។

ពូជ= ន. ដំណជាតិកំណើត ។

កិលេស= ន. សេចក្តីសៅហ្មងបត្តុ ។

អនុស័យកិលេស= ន. កិលេសតូចតាច, កិលេសបន្ទាប់បន្សំ ។

រាគ:= ន. ជម្រៃក,សេចក្តីត្រេកត្រអាលបំពោះកាម ។

ទ្រាស:= ន. សេចក្តីប្រទូស្ត, កំហឹង, កំហុស ។

មេហ:= ន. អវិជ្ជា, សេចក្តីវង្វេង ។

រាលវដ្តសង្សារ= (ម.ថ.- រ៉ាត់-ដ:សង់សា)ន. លោកដែល

សត្វតែងតែងតែរន្ធាលវិលកើតវិលស្លាប់ ។

ធម៌ព្ធ= (ម.ថ.-ម៌ត) ន. ដើមហេតុ, គោលបាវចនា, គ្រឿង

សំគាល់, លក្ខណ: ។

បរមសុ្ខ= (ម.ថ. ប-រ៉ម-) ន. សុ្ខដ៏ក្រៃលែង,សេចក្តីសុ្ខ

ដ៏ឥតសុ្ខម ។

អរិយបុគ្គ:= (ម.ថ.- អ:រ៉ិយ:បុក-គល់) ន. បុគ្គល ៨ ពួក

រាប់តាំងពីអ្នកដែលបានសម្រេចសោតាបត្តិមគ្គ រៀងទៅ

ដល់អ្នកដែលបានសម្រេចអរហត្តផល ។

វិស័យ= (ម.ថ.វិសៃ)ន. គំនិត, អារម្មណ៍, សេចក្តីដឹង ។

ប្បបិដ្ឋ= (ម.ថ. ប្ប៉ុប-ដន់) ន. ជនដែលមិនទាន់សម្រេច
គុណវិសេសណាមួយ, ជនសាមញ្ញ ។

ឧ. អក្ខរកិរ៉ុដ្ឋ

ជិញ្ញជ= សរសេរជា, ជ + ិ + ញ + ្ញ + ា + ជ យ៉ាងនេះតែម្ដង, គេមិនដែលសរសេរជាជិញ្ញជ្ជ យ៉ាងនេះទេ ។

ទ្វៃទ្វ-ទ្វៃឯរ

ទ្វៃទ្វ= គេសរសេរគ្នាពីរដង ។ បំណែកខាង

ទ្វៃឯរ= ដែលមានសេចក្ដីស្រដៀងនឹងទ្វៃទ្វដែរ, គេសរសេរមានតែមួយ ។

បច្ឆ មកពីពាក្យ ពិ, គេសរសេរគ្នាពីរដងទេ ។

ពាក្យដែលត្រូវសង្កេត:

ព្រលឹងខ្មែរ
www.arrelkhmer.fr

ព- ដ៏ណ- បទ្ធ

គេសរសេរគ្នាទៀបធាំងអស់ ។

ស្រែស-ស្រែះ

ស្រែស= (ម. ថ. វែស) គុ. ដែលស្រស់: អាហារ
ស្រស់, របស់ស្រស់ ។

ស្រែះ= ន. បស្ចិមទិសតូចតុប្បាទ (ស្រែះជាសត្វខ្លាំងហួស
មាឌ តាំងប៉ុនធន់ទ្រាំក្តៅនឹងត្រជាក់ផង) ។

ស្រែះ= ន. ឈ្មោះក្តាមសម្បុរខ្មៅយ៉ាង (គេថា
ទន្លេមានក្តាមស្រែះនៅកំពត) ។

៣៤. អធ្យាស្រ័យក្នុងព្រះពុទ្ធសាសនា

ព្រះសម្មាសម្ពុទ្ធទ្រង់ពន្យល់ពុទ្ធបរិស័ទឲ្យដឹងច្បាស់ន្ថែរ

ដើមហេតុដែលមានកស្តុតាងពីតក្រោកជ ហើយទ្រង់ដឹកនាំ
សត្វឲ្យប្រតិបត្តិតាមដោយវិធីទេសនា នឹងចរិយាសាស្ត្រ ។
ទ្រង់មានអធ្យាស្រ័យទោរទន់អាណិតសត្វលោកដែល
កំពុងដោកឆ្ងុយជាប់ជំពាក់ក្នុងបណ្តាញក្រឹតណ្ហា ជាហេតុ ជា
បច្ច័យឲ្យមានជាតជរាព្យាធិនងមរណៈ រកទបផុតគាន, ចង
ចម្អូងឲ្យផុតពីអន្ទង់ទុក្ខ ទើបទ្រង់សំដែងធម៌វិន័យឥតឆ្គុញទ្រាន់
ដើម្បីឲ្យសត្វប្រតិបត្តិងើតាម ។ តែការទូន្មាននោះ ទ្រង់ប្រើ
តែការណែនាំពន្យល់ទាញហេតុផលមកបង្ហាញ ឲ្យបរិស័ទ
យើញប្តូបូលចិត្តបានប៉ុណ្ណោះ មិនមែនប្រើអំណាចបង្ខាំបង្ខាក់ការ
តាមកំឡាំងនោះទេ្លយ ។ បើតាមបុណ្យ, ប្តូទ្រង់អំណាចនឹង
កំឡាំងកាយប្តូ កំឡាំងចិត្តរបស់ព្រះអង្គ យើញថាប្រសើរជាង
មនុស្សនឹងទេវតាមារព្រហ្មទៅទៀត, តែព្រះអង្គមានមេត្តា-

ចាយល្អ បេះដឹកនាំសត្វទ្រូងផុត ពីធម៌ជាគ្រឿងរាំងទំង
ធម៌ដែលនាំសត្វទ្រយឹតយូរ ដោយការពន្យល់បង្ហាញផ្លូវ
ដោយព្រះទ័យដ៏ខ្ជាខ្ជន់ ឥតប្រើអាការដ៏ឃោរឃៅដាហេតុ
នាំទ្រូចិត្តសើរបស់មនុស្សលោកទ្បើយ ។

ក. ពាក្យពន្យល់

អង្ករស្រែយ= (ម.ព. ភូមិអត្ថបទលេខ១៧) ។
ពន្លូបរិសែន= (ម.ព. ភូមិអត្ថបទលេខ៣១) ។
ភ័ស្តុតាង= (ម.ព. ភូមិអត្ថបទលេខ១១) ។
ប្រតិបត្តិ= (ម.ព. ភូមិអត្ថបទលេខ៣៣) ។
បរិយាសាស្ត្រ= (ម.ព. ភូមិអត្ថបទលេខ៣៣) ។
បណ្តាញ= ន. អ្វីៗដែលមានក្រឡាប្រាក់ជាសំណាញ់ ។
តណ្ហា= (ម.ព. ភូមិអត្ថបទលេខ៣៦) ។
បប៉ូយ= (ម.ព. ភូមិអត្ថបទលេខ៣៧) ។

ជីវ៉ា= ន. សេចក្តីគ្រាំគ្រា, សេចក្តីចាស់ទ្រុឌទ្រោម ។

ពុទ្ធជិ= ន. ជម្ងឺ, រោគ, អាពាធ ។

មរណៈ: ន. សេចក្តីស្លាប់ ។

ទេវតា= ន. អមនុស្សដែលជាទិព្យ ។

មារ= ន. ឈ្មោះទេវបុត្រដែលជាសត្រូវបំពោះព្រះពុទ្ធ ។

ព្រហ្ម= (ម.ថ.ព្រំ) ន. ទេវតាដែលកើតនៅព្រហ្មលោក ដោយអំណាចផលនៃឈានចិត្ត ។

មធ្យោបាយ= (ម.ព. ក្នុងអត្ថបទលេខ១៤៤) ។

យោរយៅ= គុ. ហៅហាន; ក្លាខ្លាំងឥតមានមេត្តាប្រណី ។

ទឹកចិត្តសើរ= ចិត្តដែលតាំងនៅលើដំហរឥស្សរភាព ។

១. អក្ខរក្រមខ្មែរ

អធ្យាស្រ័យ= គប្បីសរសេរជា «អ + ធ + ឫ + ។

+ស+្រ+ ់ +យ, យ៉ាងនេះតែម្ល៉ាង, គេមិនដែល

សរសេរជា: អាឡ្យាស្រ័យ យ៉ាងនេះទេ្វយ ។

កម្ម-កាំ

កម្ម= (ម.ថ. កាំ) ន. អំពើ(បុគ្គលត្រូវមានកម្មជាវេបស់ខ្លួន; ខ្លឹមនូវកម្មណាដែលល្អ) ។

កាំ= ន. អ្វីៗដែលរៀបជាជាន់សម្រាប់រង (កាំជណ្តើរ, កាំរនេះ) ។

ប៉ាស័ទ្ធ= សរសេរថាន៎ពីរយ៉ាងគឺ:

ប+រ+ ិ+ស+ ័+ទ្ធ= ប៉ាស័ទ្ធ នេះម្ល៉ាង ។

ប+រ+ ិ+ស+ទ្ធ+ ្យ= ប៉ាស័ទ្ធ្យ នេះម្យ៉ាង ។

បិត-បិត្ត

បិត= គុ. គាត់ជាចំណិត (ប៉ុងគេរៀបិតមហ្នឹង) ។

បិត= គុ. បិតសម្រួប (សិស្សបិតខ្មៅដៃ) ។

ប៊ិត្តិ = ន. ធម្មជាតសម្រាប់សន្សំអាវុធ (លោកគ្រូនេះ
មានបិត្តិល្អណាស់) ។

៣៦. ជាតិ

ប្រជុំពលរដ្ឋ របស់ប្រទេសដែលនៅរួបរួមគ្នា, នៅ
ក្រោមការគ្រប់គ្រងជាមួយគ្នា, រស់នៅក្នុងប្រទេសរួមគ្នា,
មានជាតិពន្ធដូចគ្នា និយាយភាសាដូចគ្នា, កាន់សាសនាត្រូវ
គ្នា មានប្រវត្តិការកើតមកនឹងទំនៀមទំលាប់ប្រពៃណីត្រូវគ្នា,
ប្រតិបត្តិច្បាប់សម្រាប់រដ្ឋត្រូវគ្នា នឹងរស់នៅក្នុងលក្ខណៈជាពួក
ជាក្រុម ជាសង្គមដោយសេចក្តីស្រឡាញ់គ្នាហៅថាជាតិ។ ជាតិ
មានគ្រឿងសំគាល់ប្រហែលគ្នានឹងរដ្ឋ តែធំជាងរដ្ឋ
គឺមានលក្ខណៈរបស់រដ្ឋនឹងលក្ខណៈរបស់សង្គមរួមគ្នា។
ជាតិជាគ្រឿងសំគាល់ស្មើ ឲ្យបុគ្គលដឹងថាខ្លួនគេជា
សមាជិករបស់រដ្ឋណា ជាពលរដ្ឋរបស់ប្រទេសណា។ បើ
មនុស្សគ្មានជាតិជាគ្រឿងសំគាល់ទេ គេមិនអាចដឹងបាន ថា
មនុស្សនោះជាជាតិអ្វី រដ្ឋក៏មិនអាចទទួលស្គាល់នូវជននោះថា
ជាពលរដ្ឋរបស់គេឡើយ។ ដូចនេះ ជាតិជាសារៈសំខាន់
បំផុត សម្រាប់បញ្ជាក់នូវតួបុគ្គលឲ្យដឹងថាជាពលរដ្ឋរបស់

ប្រទេសនេះឬប្រទេសនោះ ។

ជាតិប្រៀបដូចជាវិញ្ញាណរបស់រដ្ឋ ព្រោះជាគ្រឿងស្នែងឲ្យដឹងថាបុគ្គលណាខ្លះដែលជាពលរដ្ឋរបស់រដ្ឋ និងអាចបង្កាប់នូវបុគ្គលទុកនឹងរដ្ឋយ៉ាងជាប់បាន ។ បើមានតែរដ្ឋមិនមានជាតិ ប្រៀបដូចជាបុគ្គលដែលមានតែកាយឥតវិញ្ញាណ ។

ក. ពាក្យពន្យល់ (explications)

ជាតិ= (ម.ថ. ជាត) ន. កំណើត (race) ។

ពលរដ្ឋ= (ម.ថ.ពលរ៉ដ្ឋ)ន.ជនអ្នករស់នៅក្នុងរដ្ឋ(citoyen)។

ពូជ= (ម.ថ. ពន់) ន. ពូជពង្ស, សែស្រឡាយ(lignée)។

ប្រវត្តិការ= (ម.ថ. ប្រ-វត្-តិ-ការ) ន. ការប្រព្រឹត្តទៅ, ការរស់នៅ ។

សង្គម= (ម.ថ. សង៌-គំ) ន. ក្រុម, ការផ្គុបផ្គុំគ្នា, ការរួប

វគ្គ ឬ

សញ្ញាធិ= (ម.ថ.សាញ្ញ-ជាតិ) ន. ការកើតឯង, ការកើត
តាមធម្មតា ឬ

សមាធិក= (ម.ថ.ស:-ម៉ា-ធិក) ន. អ្នកដែលមានអំណាច
ត្រូវបូលទៅតាន់ទីប្រជុំបាន, អ្នកបូលក្នុងសមាគម (ស.
សមាធិក) ឬ

សារ:= (ម ថ.សា-រ:) ន. ខ្លឹម,សេចក្តីខ្លាប់ខ្លួន, លក្ខហាន,
គោលចារឹក ឬ

វិញ្ញាណ= (ម.ថ.វិញ្ញ.ញាណ)ន. ធម្មជាតដឹងអារម្មណ៍
ច្បាស់ ឬ

១. អក្ខរាវិរុទ្ធ (orthogiaphe)

ពុទ្ធ= អានថា ពុល់-ធ័ត់ ពីរោះជាងអានថា ព:ល:ធ័ត់ ឬ
គ្រប់ ប្រើនអានថាគ្រុប តែត្រូវសរសេរជា គ្រប់ យ៉ាងនេះរហូត

ដូចពាក្យថា

គ្រប់គ្រង= ត្រួតត្រា, ឃុំគ្រង ។

សព្វគ្រប់= គ្រប់ចាំងអស់, គ្មានសល់ ។

បង្គ្រប់= ធ្វើឲ្យគ្រប់ល្មម ។

រៀវសៃជនែត

សង្គ្រប ត្រូវសរសេរ ស្រ: វិញ

ឧ. ធ្វើ សង្គ្រប កណ្តរ ។

ប្រែពៃណីអានថា ប្រ-ពៃ-ទី តែត្រូវសរសេរជាណី ។

ពាក្យដែលមាន ណ ខាងចុងហើយត្រូវអានជា ន ។

បិទ្ធមណ៌

កែរមណ៏

បរែណ៏

គណេស

ប្រៗ



៣៧. សាសនា

កន្លងសម័យបុរាណ ចាប់តាំងពីមានជំនុំជនប្រកែកមួយ
ដែលនាំគ្នាប្រកាន់ពួកបក្សទ្បើងនោះ កិច្ចការរបស់មនុស្ស
កន្លងជំនុំជន ស្ទើរតែរាល់បែបការយ៉ាង ស្ទុះតែមានគតិ នឹង
លន្ទំនៃដំនើរប្រកបបួលទៅកន្លងផុតបុគ្គ នៃមនុស្សទាំងឡាយ
នោះជាដរាប ។ ជាកិច្ចការក្នុងស្រុកភូមិក្តីប្តូរគ្រាវស្រុកភូមិក្តី
ទ្បើតែកិច្ចការនោះ ជាកិច្ចការដែលទាក់ជាប់ដោយសេចក្តីក
គិតខាងផ្លូវចិត្ត ហៅថា គតិនឹងលន្ទំទាំងអស់ ។ ឧបនិស្ស័យ
ចិត្តថ្មើម ដែលបញ្ជាក់អាកប្បកិរិយាល្អអាក្រក់នៃជនម្នាក់ៗក្តី
ជំនឿភ័យខ្លាចក្តី សឲ្យឃើញថាជាឆ្នូនៃគតិនឹងលន្ទំរបស់
ជនណាម្នាក់ដែលផ្តើមបង្កើតទ្បើង ។ គតិនឹងលន្ទំនេះឯង
ហើយដែលហៅថា “សាសនា” ។ សាសនាអាចដឹកទឹក
ចិត្តមនុស្សឲ្យប្រកាន់ជ្រឹមាំក្នុងសរណវត្ថុ រាល់ៗសាសនា ។
មនុស្សសម័យនោះប្រកាន់ថាត្រូវឆ្លើពីរឆ្នាំង ។ តាមគតិប្តូលន្ទំ

នោះទើបនាំមកនូវសេចក្តីសុខចំរើន ឃ្លាតចេញផុតអំ
មានសេចក្តីវិនាសអន្តរាយ ។ គឺនិយាយនោះ កាលបុរាណ
សម័យគេហៅថា «លន្ទុសេយ្យសាស្ត្រ» ។ គឺនិយាយនេះ
មានប្រែនយ៉ាងផ្សេងៗគ្នា ។ គេនាំគ្នាជ្រះថ្លាតាមតែអ្នកដឹក
នាំឬអ្នកកសាងលន្ទុនោះ ។ ខ្លះតាំងឬសន្ទុនូវតណាមួយ
ឲ្យសៅជាទេវតាដ៏ស័ក្តិសិទ្ធិគ្រប់គ្រងនូវឥទ្ធិឫទ្ធិផ្សេងៗ មានអំ-
ណាចធំបំផុតលើមនុស្សគ្រប់គ្នា ។ កាលពេលតមកទើបមានអ្នក
ប្រាជ្ញខាងផ្លូវសាសនាពិតៗ រៀបចំតាំងគោលបាវចនាសាសនា
ខ្មីងផ្សេងៗ ជាប្រែន ដែលជាសាសនាពិតប្រាកដដូចជា
ពុទ្ធសាសនា គ្រិស្តសាសនានឹងឥស្លាមសាសនាជាដើម ។

ក. ពាក្យពន្យល់

សាសនា= (ម.ថ. សាស-ស:នា") ពាក្យបណ្តាំ, ពាក្យប្រៀន
ប្រដៅ, លន្ទុ (Religion) ។
សម័យ= (ម. ថ. ស: សៃ") ន. កាល,ពេលជួរលា,

ឧកាស, គ្រា ។

បុរាណ= (ម. ថ. បុ-រ៉ាណ) គុ. ចាស់, ដែលមានយូរ
ហើយ, ដែលកើតមានមុន ។

ជិដ្ឋំ= ន. ទីប្រជុំជន, ស្លុក, ប្រជុំ ។

ប្រភេទ= ន. ចំណែក, ប៉ែក, ខ្សែក ។

បក្ខ= (ម. ថ. ប៉ក្ខ) ន. ចំណែក, ប៉ែក, ស្លុក, បន ។

គតិ= (ម.ថ. គ:តិ) ន. ដំណើរ, ផែប, យ៉ាង, គំនិត ។

លទ្ធិ= (ម. ថ. ល៉ុទ-ធិ) ការយើញ, សេចក្តីយល់
យើញ, ដំនឿ ។

ឧបនិស្ស័យ= (ម. ថ. អ៊ុប៉:និសយៃស) ន. កុសលធម៌
ដែលដេកប្តូអាស្រ័យនៅក្នុងខន្ធសន្តាន គឺកុសលដែល
បានកសាងសន្សំអប់រំពុកមក, សំណាង, កព្វរព្រងវ-
សនា ។

អាកប្បកិរិយា= (ម. ថ. អាកប-ប័. កិរុយ៉ា) ន. ដំណើរ
បែបភាពនៃកាយ, ដំណើរឬលំនាំនៃកាយឬនៃបុគ្គល
ឆែឆ= ន. (ក្នុងពាក្យនេះ)កំសួល, ការបញ្ជាក់ ។
សរណាគត (ម. ថ. ស:រ: ណ:-) របស់សម្រាប់ទ្រាំ
របស់សម្រាប់ការពារដល់, របស់សម្រាប់អាង ។
សង្គីសង្គ្រោ- សៃយ៉សាស្ត្រ- សាសន៍
=(ម.ថ.- សៃ-យ:សាស) ន. ការយល់ឃើញក្រៅព្រះ-
ពុទ្ធសាសនា ។
សង្កិសង្កិ=(ម.ថ.ស័ក-សិត) គុ. ដែលមានអំណាចឬដែល
អាចឲ្យសម្រេចប្រយោជន៍បាន, ដែលខ្លាំងពូកែ, ដែលវិ-
សេសវិសាល ។
ឥទ្ធិឫទ្ធិ=(ម.ថ. ឥតធ៌ិរ៉ិត) ន. អានុភាពក្រៃលែងជាងធម្មតា,
អំណាចដ៏ស័ក្តិសិទ្ធិឬជាក់ស្តែង, ឫទ្ធិដ៏អស្ចារ្យ ។

១. អក្សរកាំរុង

ជីជ្ញ៑ សរសេរជា ជ + ◌ំ នឹង ជ + ◌ំ មិនត្រូវ
សរសេរជា ជ្ញ៑ំ ឬ ជ្ញ៑ំយ៉ាងនេះទេ ។

សន្ទ័ន. ពាក្យពីរព្យាង្គឬច្រើនព្យាង្គ ដែលមានពាក្យ
ជី នៅខាងមុខ ស្ទួតតែសរសេរជាមួយ
ជី នេះទាំងអស់ដូចជា: ជីជី, ជីទប់, ជីទាវ ជាដើម ។

អៀរលែងតែពាក្យបីមាត្រេបញ្ចឹង:

ជ្ញ៑= ក. ឬក. វ. ម្ហូលគ្នា ។

ជ្ញ៑= ន. ដំណើរវង់វិលដូចមកកន្ទុងជដែលវិញ ឧ. ដើរ
ប្រទក្សិណព្រះវិហារញ៉ាំ ។

ជ្ញ៑កន្ធង់= ន. ឈ្មោះល័ខមួយយ៉ាងហៅថាលំ ឬជ្ញ៑កន្ធង់
ប៉ុន្តែកាលបើពាក្យនេះ នៅបុងពាក្យវិញច្រើនតែសរ-
សេរជាមួយនឹងជ្ញ៑ ដូចពាក្យថា: ជ្ញ៑បជ្ញ៑, ប្រជ្ញ៑ជាដើម ។

៣៨. ព្រះមហាក្សត្រ

អាយដនជាន់ខ្ពស់បំផុតរបស់ប្រទេសហៅថា "ព្រះមហាក្សត្រ" ។ ព្រះមហាក្សត្រស្ថិតនៅលើព្រះពជបល្ល័ង្កផ្កុតពីសង្គមនយោបាយ ពុំលាយឡំនឹងពួកស្ត្រីប្រជាឡើយ ។ ប្រជាជនក្នុងប្រទេសដែលមានព្រះមហាក្សត្រគ្រប់គ្រងតែងបានកត់ត្រៀមអប់ឧក្ការដោយសារព្រះពជបារមីរបស់ព្រះអង្គ ។ ព្រះពជាទុកដូចជាមានតាបតាបង្កើតផ្កាលរបស់ប្រជាពួកព្រោះព្រះអង្គទ្រង់មានទឹកព្រះទ័យប្រកបដោយមេត្តាព្រហ្មវិហារធម៌ ។ ពាសេសពីនោះ ព្រះអង្គទ្រង់មានទស្សពិធរាជធម៌ជាលំអព្រះរាយរបស់ព្រះអង្គ ចំពោះពួកទៀត ។

ទស្សពិធរាជធម៌នោះគឺ ការប្រទានទ្រូវអំណោយដ៏ស្មោះ ១, វក្ខាសីល ១, បរិច្ចាគព្រះពជទ្រព្យសម្រាប់ប្រទេស ១, ទៀងត្រង់ចំពោះពួកស្ត្រី ១, អធ្យាស្រ័យនន់ភ្ញន់ ១, កំចាត់ចាបពីសន្ដានន ១, ពុំមានក្តីក្រោធ ១, មិនបៀតបៀនអ្នកដទៃ ១,

ខ្ពង់ ១ ន ឯកម្រៃប់ ១ ០ ត៌ ការ មិន កំ រើក ព្រះ ទ័ យ ដោយ សេចក្តី

ស រសើរ ន ឯ ន ន ា ។

ប្រដាក់ ស្រស់ ស្រប់ ជា ន់ ថ្នាក់ តម្លើ ង ព្រះ មហា ក្សត្រ របស់

ខ្លួ ន ឲ្យ ដូច ជា ស រ ណ វត្ថុ ត្រូ វ មា ន កត ព ការ ភា ព ចំ ពោះ ព្រះ អង្គ

តាម ជ ង្ហឹ ជា សេ ន ា បំ រើ ស្រប់ គោ ល ការ ណ៍ ន ា ន ា ។

ក. ពាក្យ ព ន្យល់

មហា ក្សត្រ = (ម.ថ. មហា ក្សត្តែ) ន. ស្តេច ធំ, ព្រះ ពុ ទ្ធ ជ័.

ប្រសើរ ។

អរិយ ជ ន = (ម.ថ. អ·រិ–យ:ជន់) ន. ជន ដ៏ ប្រសើរ, ជន

ដ៏ ខ្ពង់ ខ្ពស់ ។

រាជ ប ល្ល ង្ក = (ម.ថ.–ប៉ុ លល័ ង) ន. ព្រះ ទែ ន សម្រាប់ ព្រះ

រាជ ទ្រង់ គង់ ពែ ន ព្រះ ចា ន ។

ឧ យោ ប យ = (ម.ថ.ន:–) ន. ទ ចា យ ជា គ្រឿ ង វៃ ណោ ន ាំ

(politique) ។

រាស្ត្រប្រជា= (ម.ថ.ពស--ប្រជា) ន. ពួកពលរដ្ឋ, ប្រជាជន ។

ប្រយៅជន= (ម.ថ.-ជន់) ន. ពពួកនៃជន ។

អប់ខ្ញុណ្ហ= (ម.ថ.អប់-អ៊ុន) គុ. កក់ក្តៅ (réchauffé)

រាជបារម៉ី= (ម.ថ.ពច-ចារៈម៉ី) ន. គុណជាតិដ៏ល្អរបស់ព្រះរាជា, អំណាចដ៏ខ្ពង់ខ្ពស់របស់ព្រះរាជា ។

ព្រហ្មវិហារ= (ម.ថ. ព្រំម:-វិហា) ន. ធម៌ជាលំនៅនៃចិត្ត

ទសពិធរាជធម៌= (ម.ថ. ទស:ពិត-រាជ:ធ័រ) ន. ធម៌សម្រាប់ព្រះរាជា ១០ យ៉ាង ។

ព្រះវរកាយ= (ម.ថ.-វរកាយ) ន. ខ្លួនព្រះរាជា ។

បរិហ្គគ= (ម.ថ.បរិច.ចាក) គ. លះបង់, ចៃកចាយ ។

ឱដ្ឋ= (ម.ថ.ឱន-ត៏) ន. ការអត់ឱន, អំណត់ ។

កតញ្ញូភាព= (ម.ថ.ក:ត័ញ្ញ-ញ-) ន. ភាពជាអ្នកដឹងគុណ ។

១. អក្ខរាវិរុទ្ធ

ប្រលង្គ អានថា ប្រាល់-ឡាំង, ប្រសរសរសេរអក្សរមួយ
ខ្ពង់យ៉ាងនេះ ប + ល + ◌្ + ង + ក ។
ខ្ញុំណ្ហ អានថា អ៊ុន ត្រូវសរសេរជា ខ្ញុ + ណ + ហ
ឧ. ក្តៅខ្ញុំណ្ហ ។, ខ្ញុំខ្ញុំណ្ហកង់ចិត្តថាខឿងពីបាន ។
លំអ= អ្នកសរសេរគាត្រប៉ែន, ប្រែនសរសេរមាននូ ប៊ុង
តែគប្បីសង្កេតឲ្យដាយចំយ៉ាងនេះ, លំអ្ មកពីពាក្យថា ល្អ
គុ., ទៅជាន. ជា លំអ្ ។ ដូចនេះគប្បីសរសេរគ្មាននូ ប៊ុង ។
ស៊ីល= អានថា សិល តែសរសេរជា ស + ◌ី + ល
ឧ. ព្រះសង្ឃមាន់ស៊ីលជាគ្រឿងលំអ ។
ប៉ារិប្ចាគ= ត្រូវសរសេរជា: ប + រ + ◌ា + ប + ◌្ច + ា
+ គ ឧ. ទ្វាសកប៉ារិប្ចាគនូវធនធានដើម្បីធ្វើបុណ្យ ។
អង្ឃាស្រ័យ= ត្រូវសរសេរទំង អ + ង្ឃា + ស្រ័យ កុំ

សរសេរជា អា + ធ្យា + ស្រ័យ យ៉ាងនេះទៀយ ។

សរស្រ៌ែ= *សរសេរជា* ស + រ + ស្រ៌ែ + រ ។

៣៩. ពលរដ្ឋ

ជនណាដែលស្នាក់នៅដោយរស្មោះបូលជាជាតិនេះឬជាតិ
នោះ ហៅថាពលរដ្ឋ ។ ពលរដ្ឋនីមួយ ។ មិនមែនចាំបាច់
តែនៅអាស្រ័យក្នុងរដ្ឋជាមួយគ្នាជាដរាបនោះទេ ។ ពលរដ្ឋ
របស់ជាតិអាចនឹងអាទេសជាតិរបស់ខ្លួនឲ្យទៅជាពលរដ្ឋរបស់
ជាតិដទៃបានតាមរយៈក្តីស្នាក់ ។ រីឯដែលបានបែងជាតិរួច
ហើយ ជននោះក៏ក្លាយទៅជាពលរដ្ឋរបស់ជាតិដទៃយ៉ាងដូច
ស្រឡះ ។ មានសញ្ជាតិថ្មីប្រែជំនួសសញ្ជាតិចាស់របស់ខ្លួន ។
រដ្ឋក៏ត្រូវទទួលនូវកំហាតមួយយ៉ាងធំ ព្រោះត្រូវគាត់បញ្ជី
បម្រែនគ្រួសារអស់មួយ ក្នុងពេលនោះ ។

ពលរដ្ឋក្នុងរដ្ឋណាមួយ នាំគ្នាអាក្សៀសខ្លួនទៅប្រកបអា-
ជីវកម្មក្នុងទីដទៃ ក្រៅពីរដ្ឋរបស់ខ្លួន ដូចជាដីដែលទើបទឹង
ស្មៅឯរកយើញថ្មីឬដីត្រង់កន្លែង ដែលនៅមិនទាន់ចំរើនជារដ្ឋ
តាំងខ្លួនជាអ្នកគ្រប់គ្រងផែនដីត្រង់ភាគនោះ មានរដ្ឋកិច្ចល

របស់ខ្លួនជាប់ជាយទៀក មិនឡើងប្តូមិនរួមទឹងរដូដើម
របស់ខ្លួនទេឡើយ ហៅថា «ពលរដ្ឋអាក្រៀសខ្លួន» ។ រដ្ឋបី
ដែលពលរដ្ឋអាក្រៀសនោះគ្រប់គ្រងហៅជារដ្ឋអាក្រៀស ។

កងហាន: នៃយើងជាពលរដ្ឋម្នាក់ យើងមិនត្រូវឲ្យប្រទេស
ខាតបង់ទឹងនៃយើងដែលជាពលរដ្ឋល្អទេឬ ព្រោះថាពលរដ្ឋ
ល្អប្រទេសបំរើន ។

ក. ពាក្យពន្យល់

ស្ងួត = (ម.ថ. ស្ងាត់) គ. ពេញចិត្តប្លែកដាមួយ, ពេញ
ចិត្តឆ្ងែខ្លួនឯង ។

អាទេស = គ. ប្លែង, ផ្ទាស់ប្រែ, ផ្ទាស់ឲ្យប្លែកពាក្យ
ដើម ។

កំហាត = ន. ការខាតបង់ ។

អាក្រៀស = គ. ក្រៀសខ្លួនមិនឲ្យគេស្គាល់, គេចវៀរក្រៀស

អាណិកម្ម = (ម.ថ. អា-ណ វ៉:កម) ន. របរសម្រាប់បំពេញ
ដីវិត ។

ភាគ = ន. ចំណែក, ចែក ។

រដ្ឋាភិបាល = (ម.ថ. រ័ត-ឋា ភិ-បាល) ន. អ្នកគ្រប់គ្រង
រក្សាប្រទេស (ដណាធិការគ្រប់គ្រងពាក្យ) ។

១. អក្ខរាវុន្ធ

ស្ត្រគ្រ = អានថាស្ត្រ, សរសេរជា: ស + ្ត + ្រ + គ + ្រ ។

រដ្ឋ = អានថារ័ត្ថ, សរសេរជា រ + ដ្ឋ + ្ត ។

ពាក្យដែលជាសទិសស័ព្ទនឹងពាក្យរដ្ឋ ។

រ័ត្ថ = ន. ស្រុងគ្រប់យ៉ាង, កែវ, ពេជ្រ ។

រដ្ឋ = ន. ដែន, ប្រទេស, ឧ. ខ្ញុំនៅក្នុងរដ្ឋខ្មែរ ។

ដ ន ដ

កាលបើពាក្យមានតាំងពីរព្យាង្គទៀងទៅ, គេត្រូវសរ-

សេរនដ (គ្មានអស្លា) ។

ដដែលៗ= និយាយដដែលៗ ។

ដនែ= អ្នកនោះមានបិត្តដូនែពីខ្ញុំ ។

ដរាប= ដរាបណាខ្ញុំឈប់រៀន ដរាបនោះទើបខ្ញុំចង់

ឆ្លើសារ ។

ដន្ទឹងម្ដងដលែង= អស់កាលដលង់ខ្ញុំមិនដែលឃើញ

លោកគ្រូសោះ ។

រឿងលេងតែ

ដំហែយ= ក្រុមសាធដំហែយដោយចង្ក្រង់នេះចេញ ។

បំពោះ ដ្បិ (មានអស្លា) នេះជា ន. មានសេចក្តីថាដែល

ជា ឧទ. ជនដ៏ប្រសើរ ។ ធម៌ដ៏ឧត្តម ។ ព្រះដ៏មានបុណ្យ ...

៤០ ប្រទេស

ផែនដីមួយកន្លែង ដែលជាតំបន់មួយ ៗ ប្រជុំគ្នានៅ ហៅ
ថា : « ប្រទេស » ។ ឯកូនភាពនៃប្រទេសដែលអាចនឹងលូត
លាស់ចំរុងចំរើនតទៅទៀតបាននោះ ល្អុះណាតែមានការទ្រ-
ទ្រង់ប្រទេសជាមូលដ្ឋានដែរ ។ លទ្ធិនិយមតាមន័យ អំពីកិច្ច
ការពារជាតិប្រទេស ប្រកាន់ថាប្រទេសណាដែលអាចនឹងទ្រទ្រង់
ខ្លួន ឲ្យមានសិទ្ធិសេរីភាពនឹងអធិបតេយ្យភាពយ៉ាងបរិបូណ៌បាន
ក៏ព្រោះតែប្រទេសនោះ មានការទ្រទ្រង់ជាមូលដ្ឋានពិតប្រា-
កដ ។ ដូចនេះ ការធ្វើប្រទេសឲ្យនៅក្នុងការរឹងប៉ឹងនេះឯង ជា
សិទ្ធិដែលប្រទេសទាំងឡាយត្រូវមានជាដំបូងបំផុត ។

ធម្មសាស្ត្រសាកលភ្លឺ, ការគ្រប់គ្រងសាកលភ្លឺ, ចែងថាការ
ទ្រទ្រង់ប្រទេសឲ្យរឹងប៉ឹងនេះឯងជាអណ្តាតនៃសិទ្ធិនានា ។
ប្រទេសណាដែលបានតាំងខ្លួន នៅលើដំហរឹងប៉ឹងរួចហើយ
ប្រទេសនោះតែងមានអំណាចប្រឹងយ៉ាង ដូចជាមានអភ័យ-

ឯកសិទ្ធិសម្រាប់ជាតិ , សិទ្ធិរក្សាខ្លួន , សិទ្ធិការពារខ្លួន ,
មូលនិតិនិយម , បឋមបញ្ញត្តិ នៃធម្មជាតិជាដើម ។

ប្រទេសដែលមានការប្រស្រ័យទាក់ទងរវាងគ្នាទឹងគ្នារួម
បីប្រទេស ហៅថាប្រទេសត្រៃមិត្រ បើរួមគ្នាតែពីរហៅថា
ទ្វេមិត្រ ។

ប្រទេសដែលជាគាគីនៅភពដ៏មិត្តភាពដូច្នេះ រមែងបាន
ទទួលលទ្ធផលប្រើនប្រការ ដោយហេតុប្រទេសនានាពុំហ៊ាន
មើលងាយ ។

ក. ពាក្យពន្យល់

ប្រទ្វេស= ន. ស្រុក, ដែន, កន្លែងទួល ។

វិឌ្ឍនភាព= (ម.ថ.វ័ឌ្ឍន:ន:-) ន. ដំណើរកើតកាលវាលគុំ,
ភាពនៃសេចក្តីចំរើន, ការ:ឬដំណើរនាំឲ្យចំរើន ។

មូលដ្ឋាន= ន. (ម.ថ.មូ-ល័ត ឋាន) ន. ឫសគល់, ទីតាំង

(base) ឬ

លទ្ធិធិយ្យម= (ម.ថ.លទ្ធ-ធិ-ធិយ្យំ) ន. ការកំណត់តាម
សេចក្តីយល់ឃើញ ឬ

ឥតិឥយ្យ= ន. លំនាំនៃចរាចរ ឬ

សន្ទុស្សារភាព= (ម.ថ.សន្ទ-សារុ-) ន. អំណាចនឹងអំណាច
ដែលអាចធ្វើអ្វីបានតាមអំពើចិត្ត ឬ

អធិបតីភាព= (ម.ថ.អ:ធិប៉:ដី-) ន. ភាពនៃអ្នកដែលជាធំ ឬ

ធម្មសាស្ត្រ= (ម.ថ.ធ័ម-ម:សាស) ន. ចរាចរយុត្តិធម៌

សាកល= (ម.ថ. សាកល់) គុ. ដែលទូទៅក្នុងលោក
(universel) ឬ

អភ័យឯកសិទ្ធិ= (ម.ថ.ឫ.ភៃ-ឯក:សិត) ន. សិទ្ធិដែលជន
ខ្លះមានបំពោះខ្លួនម្នាក់ៗ មិនឲ្យមានភ័យមានទោសដល់ខ្លួន
ដូចជាមិនឲ្យគេចោទ រកចាប់យុំយាំធ្វើដើម ឬ

មូលនិធិយុទ្ធ= (ម.ថ.មូល:និត-និយុ) ន. ការកំណត់យក
ប្បាប់ជាប្រុសគល់ ។

បរមបញ្ញាធិ= (ម.ថ. ប៉:ប័ម-ប័ញ្ញ-ញ៉ាត) ន. សេចក្តីដែល
ញ្ញាធ
គេតែងតាំងជាដំបូង ។

ធម្មជាតិ-ជាតិ= (ម. ថ. ធ័ម-ម:ជាត) ន. ធម៌, សភាវៈ
ធ
(Nature) ។

ត្រៃមិត្ត= (ម. ថ. ត្រៃ-មិត) ន. មិត្តប៉ី ។
ធ

ទ្វៃមិត្ត= (ម. ថ. ទ្វៃ-មិត)ន. មិត្តពីរ ។
ធ

ភាគី= ន. ចំណែក, ប៉ែក ។

មិត្តភាព= (ម. ថ. មិត-ត:ភាប) ន. ភាពប្តូការៈនៃ
ធ
មិត្រ, បែបបទប្តូសណ្តាប់ធ្នាប់របស់មិត្រ(Amitié) ។

លទ្ធផល= (ម. ថ . ល៉ុត-ធ:ផល់) ន. ផលដែល
ធ
បានសម្រេចហើយ (Résultat) ។

១. អក្ខរាវុន្ធ

កាត់ ទង គាត់

កាត់= កិ. សរសេរបំណាំ ឧទា. ប្អូនអ្នកកត់ត្រាទុកទូរសេចក្តីណាដែលយើងមិនទាន់យល់ច្បាស់ ។ ពាក្យកត់ពន្ធអំពីអ្នកស្រុក ។

កាត់= កិ. ទប់, ឃាត់ទុកឲ្យនឹង ឧទា. ដំរីឈ្លបគេយកកង្វេរគាប់កត់ឲ្យនៅនឹង ។

គាត់= ប៊ុ. គេ, អ្នក ឧទា ម្ចាយមីងខ្ញុំ មិនបានមក ដោយគាត់មិនស្រួលសប្បាយ ។

កា-ការ-ការណ៍

កា= ន. បំពង់សម្រាប់ដាក់ទឹក, កំសៀវ ឧទា. នែ! ក្មេង យកកាទៅដាក់ទឹកមកផឹក ។

កា= កិ. សរសេរប៊ុះឈ្មោះទីលំនៅនៅលើខ្នងសំបុត្រ

ន. គារស្រោមសំបុត្រ ។

កាណ៌= (ម.ថ.គា)ន. ត្រចៀកន.ព្រះគាណៀព្រះពជា។

កាវ= ក. ម្ហូរសរសៃសុត្រ, សរសៃអំបោះ ជាដើម

ដោយខ្លាវ ន.អ្នកត្បាញ គារសុត្រ ដើម្បីធ្វើត្បាញហូល ។

កាវ= ក. បិទបាំង, រាំងរា, ឃាត់ខាំង ន. គារមិន

ឲ្យសុត្រូវបូលមក ។

កាវ= ន. កិច្ចប្រឹងអំពើដែលត្រូវធ្វើ ន. អ្នកអញ្ជើញ

មកនេះ មានគារអ្វីដែរ?

ការណ៌= ន. ហេតុ, ដំណើរ ន. ឯងធ្វើនេះ ម្ដុ

ជាទស់គារណ៌ហើយ ។

អនុសាវរីយ៍មហាវិសាមគាល

ថ្ងៃ ៥ កញ្ញ ១៩៥៦

ន.គោវិន

ពាក្យខុសត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
វណ្ណ	វណ្ណៈ	២	១
ចង់ការត្រូវដឹង	ចង់ត្រូវការដឹង	៦	៩
ការប្រព្រឹត្តិ	ការប្រព្រឹត្ត	៨	៣
ដើម្បី	ដើម្បី	៨	១៤
រកាលតាជាត	រកាលតាជាតិ	២២	៤
។ខ	។ខ		
យ៉ិតយោង	យ៉ឹតយោង	២៥	២
ប្រព្រឹ្តិ	ប្រព្រឹ្ត	២៩	១៣
intelligent	intelligence	៣៦	៥
ផ្លែក	ប្លែក	៣៩	៤
តែកំរើក	ឥតកំរើក	៤១	១១
(២៣)	(២៦)	៤២	១២
ស្ពៅស្តី	ស្ពៅស្តី	៤៥	៨

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
(ម.ប. ដន់)	(ម.ប. ដន)	៥១	៥
ពាក្យពន្យ	ពាក្យពន្យល់	៥៨	៨
សេចក្តីប្រុងស្តិ	សេចក្តីប្រុងប្រយ័ត្ន	៦៨	៨
ការន់ប្រយោជន៍គេ	ការត់ប្រយោជន៍គេ	៧៨	៩
ផ្ទិត	ភ្ជិត	៧៩	៦
រការហាត់	ការហាត់	៩០	៣
ខុតឯខុតម	ខុតឯខុតម	៩១	៣
ជ្រុំជ្រែង	ជ្រោមជ្រែង	១០២	១០
អត្ថបទលេខ ២៣	អត្ថបទលេខ ១៨	១០៥	១០
អត្ថបទលេខ ២៧	អត្ថបទលេខ ២៦	១១១	៩
អត្ថបទលេខ ២៣	អត្ថបទលេខ ១៨	១១១	១១
អត្ថបទលេខ ១៤	អត្ថបទលេខ ៩	១២២	៨
អត្ថបទលេខ ១៦	អត្ថបទលេខ ១១	១២៦	១៤
ខុតឯខុតម	ខុតឯខុតម	១២៨	៣

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
គុណជាតិឬគុណជាតិ	គុណជាតិឬគុណជាត	១២៨	៤
អត្ថបទលេខ ២៨	អត្ថបទលេខ ២៣	១៣២	១១
moralie	morale	១៥៩	៦
៣៥ ន៎ាន	៣៤ ន៎ាន	១៦១	១
៣៤អធ្យាស្រ័យ...	៣៥អធ្យាស្រ័យ...	១៦៦	១
ធម្មជាតិឬ—ជាតិ	ធម្មជាតិឬ—ជាត	១៩៣	៦
លទ្ធផល	លទ្ធផល	១៩៣	១៣

www.angkorthmarathse.ir

ផ្សាយចេញពីបណ្ណាគាររស្មីកម្ពុជា

លោកនីតិ (គឹម-វិសុត)

អក្ខរាវិរុទ្ធតាមវេយ្យាករណ៍ (គឹម-វិសុត)

វចនានុក្រមខ្មែរបារាំងភាគ១-២ (រ-គេរីម)

វេយ្យាករណ៍ដោយរូបភាព (ឌុ.គាមម៉ង់)

៤០សរសៃរតាមសង្ក្រាន្ត (រ.គេរីម)

កំពុងបោះពុម្ព

ភាសាជាតិ (Methode pratique de langage e

de lecture (A.B.C.) (គឹម-វិសុត)

(Lecture française expliquée en cambodgien

(គឹម-វិសុត)

អត្ថបទសំរាំងជាភាសាពន្យល់ជាភាសាហ្វាំង (គឹម-វិសុត)

វេយ្យាករណ៍អង់គ្លេសពន្យល់ជាភាសាហ្វាំង (ប្រស៊ីដ្ឋបណ្ឌិត-

ចិត្រ)

ភាសាអង់គ្លេសធាប់ (ប្រស៊ីដ្ឋបណ្ឌិតចិត្រ)

លោកន័យសាស្ត្រ (មាស-ប្រពន្ធ)

ក 495
495
932

៤០ សរសេរតាមសូត្រ

សម្រាប់គ្រប់ថ្នាក់

B-248

ដោយ

ទ. ទេសាទិន

ការផ្សាយរបស់

លេខ ១៩-២១ វិថីព្រះបន្ទូលជា

ក្រុងភ្នំពេញ

បោះពុម្ពផ្សាយលើកដំបូងចំនួន ១.២០០ ក្បាប់

ព. ស. ២៤៩៩ គ. ស. ១៩៥៦

រក្សាសិទ្ធគ្រប់យ៉ាង

ព្រលឹងខ្មែរ
www.prelhmerkhmer.fr